00238352

D99/3/27

# វិទ្យាស្ថានដើម្បីយុត្តិធម៌ និងច្បាប់ព្រហ្មទណ្ឌ
# នាយកដ្ឋានច្បាប់ព្រហ្មទណ្ឌបរទេស និងអន្តរជាតិ


**សាស្ត្រាចារ្យ បណ្ឌិត** K. Ambos, ចៅក្រមរបស់តុលាការរដ្ឋ, Platz der Göttinger Sieben 5, 37073

---

*Platz der Göttinger Sieben 5,*
*Blauer Turm,*
*37073 Göttingen*
*Telefon: +49-0551 39-7430*
*Telfax: +49-0551 39-22155*
*E-mail: kambos@gwdg.de*
*URL: www.jura.uni-goettingen.de/kambos*


ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 07 / 11 / 2008
ម៉ោង (Time/Heure): 09 : 20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

*Datum: 2008-10-26*

## សារណារបស់អ្នកដែលមិនមែនភាគីនៃរឿងក្តី ពាក់ព័ន្ធនឹង សំណុំរឿងព្រហ្មទណ្ឌលេខ 001/18-07-2007-ECCC/OCIJ (PTC 02)*

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 07 / NOV / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: [signature]

---


* ខ្ញុំសូមអរគុណដល់ជំនួយការស្រាវជ្រាវរបស់ខ្ញុំឈ្មោះ Lydia Löhner ដែលបានជួយខ្ញុំក្នុងការរៀបចំសារណានេះ និង អរគុណដល់ Timothy Campbell ដែលបានជួយពិនិត្យមើលភាសាឡើងវិញ។



សាស្ត្រាចារ្យដែលត្រូវបានចាត់តាំង៖ សាស្ត្រាចារ្យ បណ្ឌិត Jörg-Martin Jehle
សាស្ត្រាចារ្យ បណ្ឌិត Kai Ambos, សាស្ត្រាចារ្យ បណ្ឌិត Gunnar Duttge,
សាស្ត្រាចារ្យ បណ្ឌិត Uwe Murmann
សាស្ត្រាចារ្យ បណ្ឌិត Maria-Katharina Meyer, សាស្ត្រាចារ្យ Fitz Loos
សាស្ត្រាចារ្យ បណ្ឌិត Manfred Mailwald, សាស្ត្រាចារ្យ បណ្ឌិត Hans-Ludwig Schreiber

00238353

D99/3/27

## ខ្លឹមសារសង្ខេប

១. តាមទស្សនៈមនោគតិនិយម (សូមមើលខាងក្រោមត្រង់ចំណុច I. 2.) គេប្រើប្រាស់គោលការណ៍សហកម្មឧក្រិដ្ឋកម្មរួមនេះ ដើម្បីចោទប្រកាន់ចំពោះអំពើឧក្រិដ្ឋ ឬផលនៃការចូលរួមជាសម្ហាភាពក្នុង *សហកម្មឧក្រិដ្ឋកម្ម* ("រួម") របស់ជនទាំងឡាយ។ ពាក្យថា "សហកម្មឧក្រិដ្ឋកម្ម" គឺសំដៅលើការឯកភាពគ្នារួម ឬ ការយល់គ្នាជារួមមួយ ដោយច្បាស់លាស់ ឬមិនច្បាស់លាស់ ដើម្បីប្រព្រឹត្តអំពើឧក្រិដ្ឋជាក់លាក់ផ្សេងៗ ដើម្បីសម្រេចគោលបំណង ឬទិសដៅឧក្រិដ្ឋចុងក្រោយមួយ។ សន្និទានភាពសំខាន់នៃសហកម្មឧក្រិដ្ឋកម្មរួម ដែលជាលក្ខណៈស្នូលនៃសហកម្មឧក្រិដ្ឋកម្មរួម គឺ**គោលបំណងឧក្រិដ្ឋរួមគ្នា**[1] របស់អ្នកចូលរួមក្នុងគម្រោង។ គោលបំណងរួមគឺជាធាតុផ្សំរួមនៃគោលការណ៍សហកម្មឧក្រិដ្ឋកម្មរួម ដែលផ្សារភ្ជាប់ទំនាក់ទំនងរវាងសមាជិកខ្លួនឯង[2]ជាមុនសិន មុននឹងប្រែក្លាយវាជា**ទ្រឹស្តីនៃការទទួលខុសត្រូវសម្ហាភាពមួយ**។

២. **សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី១** គឺដូចគ្នានឹង *ការប្រព្រឹត្តិរួម* ដ្បិតអ្នកចូលរួមធ្វើទៅតាមផែនការរួម ("គម្រោងរួម" ឬ "សហគ្រាសរួម") មួយ។ ប្រសិនគេបកស្រាយ សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី១ ថា មានធាតុផ្សំសត្យានុម័តិ និងអត្តនោម័តិ ដែលជាការបកស្រាយក្នុងន័យជាក់ស្តែង គេអាចចាត់ទុកវាថាជាទម្រង់នៃការប្រព្រឹត្តរួម ក្នុងរង្វង់អត្ថន័យនៃមាត្រា ២៥(៣)(ក) alt. ២ លក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ និងជា*ទម្រង់នៃការប្រព្រឹត្តិ* អនុលោមតាមមាត្រា ៧(១) របស់លក្ខន្តិក ICTY/ មាត្រា ៦(១) របស់លក្ខន្តិក ICTR។ **សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី២** អាចចាត់ទុកថាជាទម្រង់រងមួយនៃ**សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី១** នេះប្រសិនបើគេបកស្រាយវាតាមរបៀបចង្អៀតចង្អល់។ ប៉ុន្តែបើតាមន័យទូលាយនៃការពង្រីកនៃការទទួលខុសត្រូវវិញ **សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី២** នេះគឺដូចគ្នានឹង**សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី៣**។ **សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី៣** មិនអាចចាត់ទុកថាជាទម្រង់នៃការប្រព្រឹត្តរួមទេ ប៉ុន្តែគេចាត់ទុកវាថាជាទម្រង់នៃការ *ជួយនិងជម្រុញ* គម្រោងឧក្រិដ្ឋនោះ។ វាគឺជា *ទស្សនៈស្វ័យភាព* នៃការចោទប្រកាន់ ដែលមិនបង្កើតបានជា *ការប្រព្រឹត្តិ* ដូចន័យក្នុងមាត្រា ៧(១) នៃលក្ខន្តិក ICTY/មាត្រា ៦(១) នៃលក្ខន្តិក ICTR ទេ។ តាមពិត **សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី៣** បង្ហាញច្បាស់អំពីភាពដូចគ្នានៃគោលការណ៍**សហកម្មឧក្រិដ្ឋកម្មរួម**ទៅនឹងការទទួលខុសត្រូវនៃការសមគំនិតតាមបែបប្រពៃណី ដោយវាដាក់អ្នកចូលរួមណាមួយនាក់ក្នុងសហកម្មឧក្រិដ្ឋកម្មឲ្យទទួលខុសត្រូវ

---

1

2

00238354



ចំពោះបទឧក្រិដ្ឋទាំងឡាយដែលអ្នកចូលរួមដទៃទៀត ទោះបីមិនបានឯកភាពគ្នាច្បាស់លាស់ពីដំបូងក៏ដោយ ឲ្យតែបទឧក្រិដ្ឋទាំងនោះគេអាចព្យាករដឹងមុនបាន។ ដូច្នេះការទទួលខុសត្រូវនេះ គឺផ្អែកលើភាពជាសមាជិកនៅក្នុងក្រុមដែលអនុវត្តសហកម្មឧក្រិដ្ឋកម្មរួមនោះ និងមានការខ្វែងគ្នាជាមួយនឹងគោលការណ៍ *ភាពដែលគួរដាក់ទណ្ឌកម្មបាន*។

៣. ចំពោះការអនុវត្តគោលការណ៍សហកម្មឧក្រិដ្ឋកម្មរួម**នៅចំពោះមុខ អ.វ.ត.ក** (ផ្នែកទី II នៃសារណានេះ) នេះមានន័យថាគេត្រូវតែចែកគ្នាឲ្យដាច់រវាងទម្រង់ទាំងបីរបស់សហកម្មឧក្រិដ្ឋកម្មរួម។ ការសាកល្បងដែលអាចយកវាមកអនុវត្តបានគឺយកចេញពី**គោលការណ៍នៃភាពស្របច្បាប់**ដែលទទួលស្គាល់ដោយច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងច្បាប់ អ.វ.ត.ក (II.1)។ ក្នុងពាក្យពេចន៍នៃមាត្រា ២៩(១) នៃច្បាប់ អ.វ.ត.ក *សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី១* អាចចាត់ទុកថាជា *"ការប្រព្រឹត្ត"* ដោយវាមានន័យដូចគ្នានឹងការប្រព្រឹត្តរួមក្នុងន័យបែបប្រពៃណី។ សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី៣គ្រាន់តែតម្រូវឲ្យមានការទទួលខុសត្រូវនៃអ្នកសមគំនិត និងនៅក្នុងន័យនេះគឺមិនចាំបាច់ទាល់តែប្រព្រឹត្តទេ។ ចំណែកឯសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី២ វិញ វាអាស្រ័យលើតើគេបកស្រាយវាក្នុងន័យសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី១ ឬ សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី៣ (II.2)។

៤. ចំពោះលក្ខខណ្ឌនៃច្បាប់ទំនៀមទម្លាប់នៃសហកម្មឧក្រិដ្ឋកម្មរួមវិញ ជាថ្មីម្តងទៀត គឺគេចាំបាច់ត្រូវតែវែកញែកវាឲ្យដាច់ពីគ្នា (II.3.)។ ទោះបីជា សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី១ ត្រូវបានទទួលស្គាល់ដោយយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី២ មានន័យថាទម្រង់នេះមានរួចជាស្រេចនៅក្នុងប្រទេសកម្ពុជានៅពេលដែលគេប្រព្រឹត្តបទឧក្រិដ្ឋដែលយើងកំពុងពិភាក្សានេះយ៉ាងណាក៏ដោយ ក៏នេះមិនមែនជាករណីពាក់ព័ន្ធនឹងសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី៣ និងទម្រង់ទី២ នោះដែរ លើកលែងតែគេបកស្រាយវាក្នុងន័យចង្អៀតចង្អល់ថាវាជាទម្រង់រងនៃសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី១។ ចំណុចនេះមានចែងទទួលស្គាល់ក្នុង**ច្បាប់កម្ពុជា**ដែលមានជាធរមានក្នុងពេលប្រព្រឹត្តបទឧក្រិដ្ឋនោះ(II.4.)៖ មានតែសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី១ប៉ុណ្ណោះដែលមានជាធរមានយ៉ាងច្បាស់ ប៉ុន្តែសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី៣ ឥតមានចែងក្នុងក្រមឆ្នាំ១៩៥៦ ទេ។ ចំណែកឯ សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី២វិញ មានចែងក្នុងច្បាប់ដែរ ប៉ុន្តែគេសំដៅទៅលើទម្រង់រងនៃសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី១ទៅវិញ។ ដូច្នេះ មានតែសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី១ និងទម្រង់ទី២(ក្នុងន័យចង្អៀតចង្អល់) ប៉ុណ្ណោះដែលជាច្បាប់ ដែលគេអាចយកមកអនុវត្តបានចំពោះករណីបច្ចុប្បន្ននេះ។

00238355

D99/3/27

## មាតិកា


ចំណាប់អារម្មណ៍បឋម..........................................................................................៤

**ផ្នែកទី I ទស្សនទូទៅ**....................................................................................៤

I.១ សហកម្មឧក្រិដ្ឋកម្មរួមយុត្តិសាស្ត្រសម័យទំនើប...........................................................៤

I.២ គោលបំណង និងរចនាសម្ព័ន្ធ (“តឹងរឹង”) បែបមនោគតិនិយម........................................៧

I.៣ សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី១ និងទម្រង់ចូលរួមបែបប្រពៃណី......................................៨

I.៤ សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី២ និងទី៣ ជា ទស្សនៈនៃការចោទប្រកាន់បែប (“ប្រព័ន្ធ) ស្វ័យភាព..........................................................................................១៣

I.៥ លទ្ធផលភ្លាមៗ...........................................................................................១៥

**ផ្នែកទី II ការអនុវត្តន៍នៅចំពោះមុខ អ.វ.ត.ក**......................................................១៩

II.១ ការសាកល្បងដែលអាចយកមកអនុវត្តបាន៖ និត្យានុកូលភាពជាគោលការណ៍ក្នុង ICL........១៩

II.២ តើការទទួលខុសត្រូវនៃសហកម្មឧក្រិដ្ឋកម្មរួមមានចែងក្នុងច្បាប់អ.វ.ត.ក ដែរឬទេ?.........២១

II.៣ តើការទទួលខុសត្រូវនៃសហកម្មឧក្រិដ្ឋកម្មរួមមានចែងក្នុងច្បាប់ទំនៀមទម្លាប់ (អន្តរជាតិ) ដែរឬទេ?..........................................................................................២៣

II.៣.១ សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី១.......................................................................២៣

II.៣.២ សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី២.......................................................................២៦

II.៣.៣ សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី៣.......................................................................២៨

II.៤ តើការទទួលខុសត្រូវនៃសហកម្មឧក្រិដ្ឋកម្មរួមធ្លាប់មានចែងក្នុងច្បាប់ជាតិកម្ពុជាក្នុង ពេលវេលាដែលពាក់ព័ន្ធនោះដែរឬទេ?.........................................................២៩

II.៥ តើការទទួលខុសត្រូវនៃសហកម្មឧក្រិដ្ឋកម្មរួមដែលមាននោះ មានលក្ខណៈគ្រប់គ្រាន់ ដែលអាចឲ្យជនជាប់ចោទដឹង (accessible) និងព្យាករដឹងជាមុន (foreseeable) បានដែរឬទេក្នុងពេលវេលាដែលពាក់ព័ន្ធនោះ?..................................................៣០

**ចំណាប់អារម្មណ៍បឋម**

ម្ចាស់សារណាត្រូវបានគេសុំឱ្យរៀបចំសារណា *នៃអ្នកដែលមិនមែនភាគីនៃរឿងក្តី* នេះពាក់ព័ន្ធនឹងបញ្ហាដូចខាងក្រោម៖

១ ការវិវឌ្ឍន៍នៃទ្រឹស្តីនៃសហកម្មឧក្រិដ្ឋរួម និងការវិវត្តន៍នៃនិយមន័យទម្រង់នៃការទទួលខុសត្រូវដោយយោងជាពិសេសតែទៅលើរយៈកាលពីឆ្នាំ ១៩៧៥-១៩៧៩។

២ ការអនុវត្តន៍សហកម្មឧក្រិដ្ឋកម្មរួមធ្វើជាទម្រង់នៃការទទួលខុសត្រូវនៅចំពោះមុខ អ.វ.ត.ក ដោយផ្តោតលើអង្គហេតុមួយនៃអត្ថិភាពនៃការប្រព្រឹត្តិឧក្រិដ្ឋកម្មក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩។

ខ្ញុំនឹងបកស្រាយបញ្ហាទាំងនេះដោយញែកសារណាខ្ញុំចេញជាពីរផ្នែក។ ផ្នែកទី១ (ផ្នែកទូទៅ) (សូមមើលខាងក្រោម ត្រង់ចំណុច I.១) ដែលធ្លាប់ត្រូវបានលើកយកមកពិភាក្សាកាលពីមុនរួចហើយ[3] ខ្ញុំនឹងពន្យល់សហកម្មឧក្រិដ្ឋកម្មរួម ដោយយោងទៅលើយុត្តិសាស្ត្រសម័យទំនើប (I.១) និងគោលបំណងនិង វចនាសម្ព័ន្ធ (“តឹងរឹង”) បែបមនោគតិនិយម (I.២)។ បន្ទាប់មកទៀត ខ្ញុំនឹងប្រៀបធៀបសហកម្មឧក្រិដ្ឋកម្មរួម ទៅនឹងទម្រង់នៃការចូលរួមបែបប្រពៃណី ដើម្បីចែកចំណាត់ថ្នាក់ទម្រង់ទាំងបីនៃសហកម្មឧក្រិដ្ឋកម្មរួមដែលមានកំណត់ក្នុងយុត្តិសាស្ត្រនេះឱ្យកាន់តែច្បាស់លាស់ ដើម្បីបានជាមូលដ្ឋានសម្រាប់ការបកស្រាយរបស់ខ្ញុំនៅផ្នែកទី២ (ផ្នែកពិសេស)។ ក្នុងផ្នែកនេះ ខ្ញុំនឹងវិភាគមើលថាតើសហកម្មឧក្រិដ្ឋកម្មរួម អាចយកមកអនុវត្តបាននៅក្នុងច្បាប់ អ.វ.ត.ក បានដែរឬទេ និង/ឬ បន្ទាប់មកតើវាមានប្រតិសកម្មចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ ឬយ៉ាងណា។

## ផ្នែកទី I ទស្សនទូទៅ

### I.១ សហកម្មឧក្រិដ្ឋកម្មរួមយុត្តិសាស្ត្រសម័យទំនើប

គេអាចយោងគោលការណ៍សហកម្មឧក្រិដ្ឋកម្មរួម[4] នេះត្រឡប់ទៅក្រោយវិញក្នុងសាលដីកា[5] របស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ទាក់ទងនឹងរឿងក្តីរបស់ *តាឌិច* (*Tadic*)។ អង្គជំនុំជម្រះបានយកទ្រឹស្តីនៃការចូលរួមក្នុងឧក្រិដ្ឋកម្មអន្តរជាតិដែលពាក់ព័ន្ធនឹង *បរិបទសមូហភាព,*

---

3

4

5

00238357

D99/3/27

*សាកល និងជាប្រព័ន្ធ* ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះ ម៉្លោះហើយវាអាចជួយដោះស្រាយបញ្ហានៃការរកភស្តុតាងមួយនេះបាន ពោលគឺភស្តុតាងដែលជួនកាលពិបាកនឹងរកឲ្យឃើញតួយ៉ាងភស្តុតាងនៃការចូលរួមរបស់បុគ្គលអ្នកចូលរួមមួយនាក់ៗនេះ។ អង្គជំនុំជម្រះទទួលស្គាល់យ៉ាងត្រឹមត្រូវថា "ស្ទើរតែទាំងអស់នៃ (...) បទឧក្រិដ្ឋទាំងនេះ (...) បង្កើតបាននូវសញ្ញាណនៃការទទួលខុសត្រូវរួមផ្នែកព្រហ្មទណ្ឌ៖ បទឧក្រិដ្ឋទាំងឡាយដែលជារឿយៗធ្វើឡើងដោយក្រុមផ្សេងៗ ឬដោយបុគ្គលដែលឡាយដែលប្រព្រឹត្តឡើងទៅតាមគម្រោងឧក្រិដ្ឋរួមមួយ"[6]។ អង្គជំនុំជម្រះបានញែកឲ្យដាច់គ្នារវាងទម្រង់ទាំងបីនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ[7]ដោយផ្អែកលើយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី២ (ចំណុចនេះមានរៀបរាប់ពិស្តារ នៅខាងក្រោម ត្រង់ចំណុច II.២)៖

(១) ទម្រង់*មូលដ្ឋាន* ដែលនៅទីនេះគឺអ្នកចូលរួមប្រព្រឹត្តបទឧក្រិដ្ឋដោយផ្អែកលើមូលដ្ឋាននៃ "គម្រោងរួម" ឬ "សហគ្រាសរួម" និងដោយមាន "ចេតនា" រួម (ចាប់ពីពេលនេះតទៅ យើងហៅទម្រង់នេះថា "សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី១ ឬ JCE 1"

(២) ទម្រង់ជា*ប្រព័ន្ធ* ឧទាហរណ៍ ករណីមណ្ឌលប្រមូលផ្តុំ ដែលបទឧក្រិដ្ឋត្រូវបានប្រព្រឹត្តឡើងដោយសមាជិកនៃអង្គភាពយោធា ឬអង្គភាពរដ្ឋបាល ដូចជាអ្នកទាំងឡាយដែលមើលការខុសត្រូវមណ្ឌលប្រមូលផ្តុំ ឬមណ្ឌលឃុំឃាំងដោយត្រូវអនុវត្តតាមផែនការរួមមួយ ("គោលបំណងរួម") (ចាប់ពីពេលនេះតទៅ យើងហៅទម្រង់នេះថា "សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី២ ឬ JCE 2"

(៣) ទម្រង់សហកម្មឧក្រិដ្ឋកម្មរួមបែប*"ពង្រីក"* ដែលនៅទីនេះ ចារីមួយនាក់ក្នុងចំណោមសហចារីទាំងអស់ បានប្រឡូកក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋដែលហួសពីព្រំដែននៃផែនការរួមនោះ ប៉ុន្តែការប្រព្រឹត្តិរបស់គាត់នេះ នៅតែអាចបង្កើតបាននូវ"ផលវិបាកបែបធម្មជាតិ និងអាចព្យាករដឹងមុនបាន *[natural and foreseeable consequences]*" ពាក់ព័ន្ធនឹងការយល់ដឹងអំពីផែនការនោះ (ចាប់ពីពេលនេះតទៅ យើងហៅទម្រង់នេះថា "សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី៣ ឬ JCE 3")។

---

6

7

ធាតុផ្សំសត្យានុម័តិនៃការទទួលខុសត្រូវចំពោះសហកម្មឧក្រិដ្ឋកម្មរួមនេះមានបី៖

(១) ពហុភាពនៃចំនួនមនុស្ស

(២) អត្ថិភាពនៃផែនការរួម គម្រោងរួម ឬគោលបំណងរួម និង

(៣) ការចូលរួមរបស់ជនជាប់ចោទក្នុងសហកម្មឧក្រិដ្ឋកម្មរួមដោយទម្រង់ណាមួយនៃ "ទម្រង់នៃការជួយ ឬការបរិច្ចាកចំពោះ ការអនុវត្តន៍គោលបំណងរួមនោះ"។

ជាលទ្ធផល អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានព្យាយាមផ្តល់និយមន័យនៃធាតុផ្សំសត្យានុម័តិរបស់សហកម្មឧក្រិដ្ឋកម្មរួមឲ្យបានច្បាស់លាស់ជាងមុន ដោយការបង្កើតលក្ខណៈវិនិច្ឆ័យ[8] ដូចតទៅនេះ៖ ចំពោះពហុភាពនៃចំនួនមនុស្ស គេមិនចាំបាច់កំណត់ឈ្មោះនៃសមាជិកនីមួយៗនោះទេ, ចំពោះគោលបំណងរួម ព្រះរាជអាជ្ញាត្រូវតែកំណត់ឲ្យបានច្បាស់លាស់នូវវិសាលភាពនៃគោលបំណងធំ រយៈពេល ភូមិសាស្ត្រ ។ល។ និងត្រូវកំណត់ឲ្យដឹងច្បាស់ថាតើគោលបំណងនោះគឺប្រាកដជាគោលបំណងរួមមួយដែលសមាជិកទាំងអស់នៃសហកម្មឧក្រិដ្ឋកម្មរួម[9]សុទ្ធតែបានដឹងថាជាគោលបំណងរួមដូច្នេះមែនឬយ៉ាងណា ព្រះរាជអាជ្ញាត្រូវតែរកឲ្យឃើញនូវភស្តុតាងដើម្បីបញ្ជាក់អំពីការបរិច្ចាក[10]របស់ជនជាប់ចោទក្នុងការអនុវត្តន៍គោលបំណងនៃសហកម្មឧក្រិដ្ឋកម្មរួមនោះ។ លើសពីនេះទៅទៀត អង្គជំនុំជម្រះបានបញ្ជាក់យ៉ាងច្បាស់ថាចារីដែលប្រព្រឹត្តផ្ទាល់មិនចាំបាច់តែជាអ្នកដែលស្ថិតក្នុង JCE 1 នោះទេ ឧទាហរណ៍ អ្នកមើលការខុសត្រូវ (ឧទាហរណ៍ អ្នកដឹកនាំនៃរបបផ្តាច់ការ) អាចបង្កើតបានជាសហកម្មឧក្រិដ្ឋកម្មរួមមួយក្នុងរង្វង់ពួកខ្លួន និងអាចប្រើចារីដែលប្រព្រឹត្តផ្ទាល់ដែលមិនមែនជាអ្នកស្ថិតក្នុងសហកម្មឧក្រិដ្ឋកម្មរួមនោះ ដើម្បីការអនុវត្តន៍គោលបំណងរបស់ពួកគេ (បើទោះបីជាពួកគេអាចស្ថិតក្នុងសហកម្មឧក្រិដ្ឋកម្មរួមដូចគ្នានេះមួយទៀតជាយថាហេតុយ៉ាងណាក្តី)។ ដើម្បីធ្វើការចោទប្រកាន់ក្នុងករណីនេះបាន ពោលគឺក្នុងករណីដែលបទឧក្រិដ្ឋនេះបានប្រព្រឹត្តឡើងដោយចារី"ខាងក្រៅ"ដែលប្រព្រឹត្តផ្ទាល់ តែចារីនោះមិនមែនស្ថិតក្នុងសហកម្មឧក្រិដ្ឋកម្មរួមនេះទេនោះ ជាការចាំបាច់គេត្រូវរកភស្តុតាងមកបញ្ជាក់ យ៉ាងហោចណាស់ត្រូវរកឲ្យឃើញនូវអត្ថិភាពនៃទំនាក់ទំនងរវាងចារីដែលប្រព្រឹត្តផ្ទាល់ និងការប្រព្រឹត្តរបស់ពួកគេជាមួយ

---

8

9

10

សមាជិកយ៉ាងហោចក៏មួយនាក់នៃសហកម្មឧក្រិដ្ឋកម្មរួមនេះ ហើយសមាជិករូបនេះត្រូវតែជាអ្នកដែលបានប្រព្រឹត្តទៅតាមការព្រមព្រៀងរួមគ្នាមួយរវាងសមជិកទាំងអស់នៃសហកម្មឧក្រិដ្ឋកម្មរួម[11]នេះ។ ការអនុវត្តតាមវិធីនេះ អង្គជនុំជម្រះបង្កើតជាទម្រង់ *នៃសហចារីដែលប្រព្រឹត្តដោយផ្ទាល់ (ឬការប្រព្រឹត្តិរួមតាមរយៈអ្នកដទៃ) របស់សមាជិកទាំងឡាយនៃសហកម្មឧក្រិដ្ឋកម្មរួម* ពាក់ព័ន្ធនឹងចារីដែលប្រព្រឹត្តផ្ទាល់ ដែលក្នុងន័យនេះ មិនមែនជាឧបករណ៍តែមួយគត់របស់ចៅហ្វាយនាយនោះទេ[12]។ បើទោះជាលក្ខខណ្ឌទាំងនេះតម្រូវឲ្យអនុវត្តបានដូចគ្នាចំពោះ JCE I, JCE II និង JCE III ក៏ដោយ ក៏*លក្ខខណ្ឌអត្តនោម័តិ* របស់វាមានភាពខុសគ្នាទៅតាមទម្រង់នៃសហកម្មឧក្រិដ្ឋកម្មរួម[13]នីមួយៗ។ JCE I តម្រូវឲ្យមានចេតនារួមរបស់ចារី(សហចារី)។ JCE II ទាមទារឲ្យមានការយល់ដឹងដោយផ្ទាល់ខ្លួនអំពីប្រព័ន្ធនៃការធ្វើបាបនោះ។ JCE III ត្រូវមានចេតនា (i) ចូលរួមក្នុងគោលបំណងឧក្រិដ្ឋនោះ និងធ្វើឲ្យគោលបំណងនេះចម្រើនទៅមុខ (ii) ជួយប្រព្រឹត្តបទឧក្រិដ្ឋដែលធ្វើឡើងដោយក្រុមមួយ, ដោយអ្នកដទៃ។ ការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋណាមួយ ដែលមិនមែនជាផ្នែកមួយនៃគោលបំណងរួម គឺកើតមានឡើងបាន ប្រសិនបើការប្រព្រឹត្តបទឧក្រិដ្ឋនេះអាចព្យាករដឹងមុនបាន និងជនជាប់ចោទ(សុខចិត្តព្រម)ទទួលយកការប្រថុយប្រថាននោះ។

យុត្តិសាស្ត្រជាបន្តបន្ទាប់របស់ ICTY/ICTY នេះគឺយកទាំងស្រុងតាមសេចក្តីសម្រេច[14] ក្នុងរឿងក្តីរបស់ *ថាឌិច* ។ ចំណែកឯសាលាក្តីចម្រុះថ្មីៗវិញ គឺគេឃើញថាមានតែ **គណៈកម្មការពិសេសរបស់ទីម័រខាងកើតសម្រាប់បទឧក្រិដ្ឋធ្ងន់ធ្ងរ**[15] ដែលកន្លងមកធ្លាប់អនុវត្តគោលការណ៍សហកម្មឧក្រិដ្ឋកម្មរួមនេះ[16]។ *អង្គបុរេជំនុំជម្រះនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ* (ឬហៅកាត់ថា “ICC”) ក្នុងរឿងក្តីរបស់ លូបាំងហ្គា (Lubanga) និង កាតាំងហ្គា (Katanga) និង ង្គូចូឡូ (Ngudjolo)[17] បានផ្តាច់ខ្លួនចេញពីគោលការណ៍សហកម្មឧក្រិដ្ឋរួមនេះ ដោយយ៉ាងហោចណាស់ ខ្លួនបានចូលជ្រៅហួសពីសហប្រព្រឹត្តិក្នុងន័យរបស់មាត្រា ២៥(៣)(ក) នៃលក្ខន្តិករបស់ ICC ឧទាហរណ៍ ភាពជាប្រព័ន្ធរបស់ខ្លួន(JCE II) និងទម្រង់ពង្រីក(JCE II)។

11
12
13
14
15
16
17

D99/3/27

គេនៅរង់ចាំមើលនៅឡើយ ដោយមិនដឹងថាតើសេចក្តីសម្រេចដំបូងៗទាំងនេះគឺជាសញ្ញាណប្រាប់យើងឲ្យដឹងថានេះគឺជាការប្រើប្រាស់គោលការណ៍សហកម្មឧក្រិដ្ឋកម្មរួមជាចុងក្រោយនៅតុលាការ ICC[18] ឬយ៉ាងណាទេ។

## I.២ គោលបំណង និងរចនាសម្ព័ន្ធ (“គឺចរឹង”) បែបមនោគតិនិយម

គេប្រើគោលការណ៍សហកម្មឧក្រិដ្ឋកម្មរួមដើម្បីចោទប្រកាន់ចំពោះអំពើឧក្រិដ្ឋមួយចំនួន ឬចំពោះលទ្ធផលនៃការចូលរួមរបស់មនុស្សទាំងឡាយក្នុង*សហកម្មឧក្រិដ្ឋកម្មសមូហភាព* (“រួម”)។ ពាក្យថា “សហកម្មឧក្រិដ្ឋកម្ម”នេះ មានន័យថាជាការព្រមព្រៀងគ្នា ឬការយល់គ្នារួមមួយ ទាំងធ្វើដោយច្បាស់លាស់ ឬមិនច្បាស់លាស់ ដើម្បីប្រព្រឹត្តអំពើឧក្រិដ្ឋជាក់លាក់មួយចំនួន ដើម្បីសម្រេចគោលបំណងឧក្រិដ្ឋរួម ឧទាហរណ៍ ក្នុងករណីសហកម្មប្រល័យពូជសាសន៍, គោលបំណងបំផ្លាញក្រុមជាគោលដៅណាមួយឲ្យផុតពូជអស់។ សហកម្មសាកល ឬទូលំទូលាយបែបនេះ តាមធម្មតា មានសហកម្មរង[19] (“បន្ទាប់បន្សំ”) ជាច្រើនផ្សេងៗទៀត មានដូចជា ការមើលការខុសត្រូវជំរំប្រមូលផ្តុំ ឬជំរំឃុំឃាំងសមាជិកនៃក្រុមគោលដៅណាមួយ, ការធ្វើទុកបុកម្នេញដោយមានអង្គការចាត់តាំងក្នុងស្រុក ឬក្នុងតំបន់ ទៅលើសមាជិករបស់ក្រុមណាមួយ[20] ។ល។ អ្នកចូលរួមនៅក្នុងសហកម្មនោះគឺជាប់កាតព្វកិច្ចរួមគ្នា ដោយពួកគេមាន *ឆន្ទៈរួម* ដើម្បីសម្រេចគោលបំណងចុងក្រោយមួយឲ្យបាន តាមមធ្យោបាយចាំបាច់ទាំងឡាយដែលមាន ឧទាហរណ៍ តាមរយៈបទឧក្រិដ្ឋទាំងឡាយដែលត្រូវប្រព្រឹត្តឡើងរហូតដល់បានសម្រេចគោលបំណងឧក្រិដ្ឋចុងក្រោយនោះ។ គោលគំនិតចម្បងនៃសហកម្មឧក្រិដ្ឋកម្មរួមនេះគឺផ្តោតជាសំខាន់លើ **គោលបំណងឧក្រិដ្ឋបូកបញ្ចូលគ្នា សហការគ្នា ឬរួមគ្នា**[21] នៃអ្នកចូលរួមនៅក្នុងសហកម្មនោះ។ គោលបំណងរួមគឺធាតុផ្សំរួមនៃគោលការសហកម្មឧក្រិដ្ឋកម្មរួម ដែលផ្សារភ្ជាប់សមាជិកនីមួយៗភ្ជាប់គ្នាក្នុងរង្វង់ពួកខ្លួន[22] និងប្រែក្លាយវាទៅជា**ទ្រឹស្តីទទួលសុខត្រូវរួម** ដែលផ្អែកលើការចូលរួមដែលមានលក្ខណៈចាត់តាំង[23] ឬទម្រង់នៃចោទប្រកាន់ជាលក្ខណៈប្រព័ន្ធ[24]។ អាស្រ័យ

---

18

19

20

21

22

23

24

00238361

D99/3/27

ហេតុនេះ គោលការណ៍នេះគឺបង្កើតបានជាច្បាប់សមគំនិត[25] និងការទទួលខុសត្រូវក្នុងនាមជាសមាជិក ឬអង្គការចាត់តាំង ដែលត្រូវបានគេយកមកអនុវត្តនៅ ញូរ៉ឹមប៊ើក (Nuremberg)[26]។ ការពន្យល់ទូទៅនេះ ចាំបាច់ត្រូវមានលក្ខណៈខុសគ្នាបន្ថែមទៀតពាក់ព័ន្ធនឹងទម្រង់ទាំងបីនៃសហកម្មឧក្រិដ្ឋកម្មរួមដែលបានកំណត់ក្នុងយុត្តិសាស្ត្រ។ ដូច្នេះ ចំណុចនេះសង្ខេបអំពីការវិភាគមួយអំពីសហកម្មឧក្រិដ្ឋកម្មរួមពាក់ព័ន្ធនឹងច្បាប់ប្រពៃណីស្ដីពីការចូលរួម។

## I.៣ សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី១ និងទម្រង់ចូលរួមបែបប្រពៃណី

ស្របពេលដែលគោលការណ៍បែបប្រពៃណី (ជាតិ) មិនអាចប្ដូរគ្នាបានដោយគ្មានច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ឬហៅកាត់ថា (ICL) ដ្បិតវាផ្ដោតទៅលើតួនាទី និងការចូលរួមបរិច្ឆាករបស់ចារីដោយបុគ្គលម្នាក់ៗ ជាជាងចូលរួមក្នុងទម្រង់សមូហភាព ឬប្រព័ន្ធទេ។ ប៉ុន្តែ វានៅតែអាចជួយពន្យល់ និងរៀបចំទៅជាប្រព័ន្ធនូវទម្រង់នៃការចោទប្រកាន់ និងការចូលរួមក្នុងច្បាប់ ICL។ វាចែងអំពីទម្រង់នៃការទទួលខុសត្រូវសមូហភាព ជាឧទាហរណ៍នៃការសមគំនិត និងការបង្ហាញអំពីការទទួលខុសត្រូវក្នុងនាមជាសមាជិក។ តាមការពិតគោលការណ៍សហកម្មឧក្រិដ្ឋកម្មរួមនេះគឺមានពីមុន ដូចជា *ទ្រឹស្ដីគោលបំណងរួម*[27]របស់អង់គ្លេស ឧទាហរណ៍ ប្រភេទនៃការប្រព្រឹត្តរួមដោយសត្យានុម័តិ។ តាមទស្សនៈខ្វែងគ្នាអំពីការចូលរួមនេះ ពាក្យថាការប្រព្រឹត្តិរួម និងការចូលដៃគ្នា (ជួយ និងជម្រុញ) គឺមានសារៈសំខាន់ណាស់ និងដើរទន្ទឹមគ្នាជាមួយនឹងកម្រិតនៃការចូលរួម (សត្យានុម័តិ) នៅក្នុងផែនការឧក្រិដ្ឋ (អត្តនោម័តិ) នោះ។ ម៉្យាងទៀត នៅពេលដែលកម្រិតនៃការចូលរួមថយចុះ ការចូលរួមប្រព្រឹត្តកាន់តែខិតចូលជិតទៅនឹងពាក្យថា ជួយនិងជម្រុញ ដូច្នេះនិយមន័យរវាងពាក្យទាំងពីរនេះកាន់តែមានភាពមិនច្បាស់លាស់។

ស្របពេលដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍ក្នុងករណី ថាឌិច មិនបានបញ្ជាក់ឲ្យបានច្បាស់អំពីថាតើគោលការណ៍សហកម្មឧក្រិដ្ឋកម្មរួមនេះគឺយកចេញពីច្បាប់ជាតិត្រង់ចំណុចនៃការចូលរួម ឬបង្កើតឲ្យមានទម្រង់នៃការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌថ្មី និងស្វ័យភាពមួយឬយ៉ាងណានោះ សាលដីកាមួយយ៉ាងហោចណាស់ក៏បានទទួលស្គាល់បញ្ហាមួយចំនួននៃ**ទម្រង់ត្រឹមត្រូវនៃការចូលរួមនេះ** និងសម្រេចជ្រើសរកដំណោះស្រាយបែបអត្តនោម័តិមួយទៅវិញ។ នៅក្នុងរឿងក្ដី ខ្វុចកា (Kvocka) និងរឿងក្ដី

25

26

27

អ្នកផ្សេងទៀត អង្គជំនុំជម្រះសាលាដំបូង មិនបានយល់ស្របជាមួយនឹងសាលដីកាឧទ្ធរណ៍ក្នុងរឿងក្តីថាឌិច នោះទេ។ អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកការជួយនិងជម្រុញនេះទៅតាមទម្រង់ប្រពៃណីរបស់វា និងអាចយកវាមកអនុវត្តបានទាក់ទងជាមួយនឹងសហកម្មឧក្រិដ្ឋកម្មរួមផងដែរ។ ខ្លួនបានយល់ថាភាពខុសគ្នារវាងការចូលរួមប្រព្រឹត្ត និងការជួយនិងជម្រុញគឺជាបញ្ហាអត្តនោម័តិ៖ ប្រសិនបើ "អ្នកចូលរួមមានចេតនារួមដូចគ្នានឹងសហកម្មឧក្រិដ្ឋកម្មនោះដែរ" គឺមានន័យថាគាត់គឺជាសហចារី ប្រសិនបើគាត់ "គ្រាន់តែ" ដឹង នោះមានន័យថាគាត់គឺជាអ្នកជួយនិងជម្រុញមួយនាក់ក្នុងសហកម្មឧក្រិដ្ឋកម្មរួម[28]។ ប៉ុន្តែ ក្នុងកថាខ័ណ្ឌមួយចំនួនតមកក្រោមទៀត អង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់ថាមានការបកស្រាយបែបសត្យានុម័តិទាក់ទងជាមួយនឹងភាពខុសគ្នានេះផងដែរ៖ ពោលគឺអ្នកជួយនិងជម្រុញអាចនឹងក្លាយខ្លួនជាសហចារីបាន ប្រសិនបើការចូលរួមរបស់គាត់ "មានរយៈពេលយូរ ឬ(គាត់) ចាប់ផ្តើមចូលប្រឡូកកាន់តែច្រើនជាងមុន[29]" ប្រភេទនៃការចូលរួមនេះ គឺអាស្រ័យលើ "មុខនាទីនៅក្នុងឋានុក្រមនៃអង្គការចាត់តាំងនោះ និងកម្រិតនៃ (...) ការចូលរួម[30]"។ សហចារីបំពេញតួនាទីសកម្មជាង "មិនចំពោះថាគាត់បំពេញតួនាទីនេះតាមរយៈការប្រព្រឹត្តិការរំលោភសិទ្ធិមនុស្សដោយខ្លួនគាត់ ឬតាមរយៈឥទ្ធិពលនៃការបញ្ចុះបញ្ចូលរបស់គាត់នោះទេ"។ អ្នកជួយនិងជម្រុញ មានតួនាទីតិចតួចជាងនេះ ពោលគឺគាត់បំពេញការងាររបស់គាត់ដោយស្ងាត់ៗ[31]។ ទោះជាក្នុងករណីណាមួយក៏ដោយ "ការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលអាចព្យាករទុកមុនបាននេះ គឺជាការទទួលខុសត្រូវរបស់អ្នកជួយនិងជម្រុញ ព្រមទាំងសហចារី" នៃសហកម្មឧក្រិដ្ឋកម្មរួម[32]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ យល់ឃើញថាគ្មានភាពខុសគ្នាខាងសត្យានុម័តិរវាងការជួយនិងជម្រុញក្នុងបទឧក្រិដ្ឋតែមួយ ឬសហកម្មឧក្រិដ្ឋកម្មរួមទេ។ ក្នុងករណីទាំងពីរនេះ វាចាំបាច់ត្រូវតែមាន "ការបរិច្ចាកច្រើនល្មម"[33]។ ភាពខុសគ្នាគឺស្ថិតនៅលើបញ្ហាអត្តនោម័តិ៖ ពោលគឺនៅពេលដែលជនជាប់ចោទជួយនិងជម្រុញបទឧក្រិដ្ឋតែមួយ គាត់ត្រូវទទួលខុសត្រូវចំពោះបទឧក្រិដ្ឋមួយនោះ បើទោះបីជាចារីសំខាន់គឺជាសមាជិករបស់សហកម្មឧក្រិដ្ឋរួមយ៉ាងណាក៏ដោយ។ នៅពេលដែលជនជាប់ចោទដឹងថាគាត់ជួយបទឧក្រិដ្ឋជាក្រុម ដែលជាផ្នែកមួយនៃសហកម្មឧក្រិដ្ឋកម្មរួម និងគាត់មានចេតនាដូចគ្នាជាមួយនឹងចេតនារបស់ក្រុមនោះ គាត់ត្រូវទទួលខុសត្រូវចំពោះការជួយធ្វើឲ្យសហកម្មឧក្រិដ្ឋកម្មនោះមានភាពចម្រើនទៅមុខ ក្នុងនាមជា

---

28

29

30

31

32

33

D99/3/27

សហចារី[34]មួយនាក់។ ក្នុងរឿងក្ដីរបស់ អុចដានិច (Ojdnanic) អង្គជំនុំជម្រះសាលាឧទ្ធរណ៍បញ្ជាក់ថាសហកម្មឧក្រិដ្ឋនោះគឺជាទម្រង់នៃការប្រព្រឹត្តិមួយ "ដោយសារតែអ្នកចូលរួមមានបំណងដូចគ្នាជាមួយនឹងសហកម្មឧក្រិដ្ឋកម្មរួម (...) ប៉ុន្តែចំណុចនេះផ្ទុយគ្នានឹងការគ្រាន់តែដឹងអំពីវា" និងដូច្នេះ "មិនអាចចាត់ទុកថាជាអ្នកជួយនិងជម្រុញតែមួយមុខបានទេ (...)[35]"។ ក្នុងន័យនេះ គឺមានន័យថាប្រសិនបើអ្នកចូលរួមគ្រាន់តែដឹង គាត់អាចត្រូវទទួលខុសត្រូវត្រឹមតែជាអ្នកជួយនិងជម្រុញប៉ុណ្ណោះ។

ប្រសិនបើយើងយកតាមការបកស្រាយទាំងនេះ បញ្ហានៃទម្រង់ត្រឹមត្រូវនៃការចូលរួមគឺមានការផ្សាភ្ជាប់គ្នាទៅនឹងបញ្ហាដែលថាតើ**ការជួយនិងជម្រុញសហកម្មឧក្រិដ្ឋកម្មរួម** អាចយកមកអនុវត្តទៅរួចដែរឬអត់។ ស្របពេលដែលអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្ដី ខ្វុចក្កា ទទួលយកទស្សនៈនេះ ខាងអង្គជំនុំជម្រះសាលាឧទ្ធរណ៍វិញគ្រាន់តែអនុវត្តការជួយនិងជម្រុញនេះ ចំពោះតែលើកម្មបទនៃការចូលដៃក្នុងបទឧក្រិដ្ឋតែឯកឯងប៉ុណ្ណោះ។ តាមការពិត ទស្សនៈបែបរឹតត្បិតនេះគឺយកតាមខ្លឹមសារនៃពាក្យពេចន៍របស់មាត្រា ៧(១) នៃលក្ខន្តិកៈរបស់ ICTY ដ្បិតមាត្រានេះមានចែងអំពីភាពខុសគ្នារវាងសហកម្មឧក្រិដ្ឋកម្មរួម ដោយរួមបញ្ចូលពាក្យ "បានប្រព្រឹត្ត"ផង និង "បានជួយ និងជម្រុញ"។ ប៉ុន្តែបើតាមទស្សនៈជាគោលការណ៍ គឺការនេះមិនចាំបាច់ទេ។ ផ្ទុយទៅវិញ បើយើងយកតាមការអនុវត្តន៍ជាក់ស្ដែងរបស់អង្គជំនុំជម្រះសាលាដំបូងចំពោះរឿងក្ដី ខ្វុចក្កា និងយកតាមច្បាប់អង់គ្លេសស្ដីពីគោលបំណងរួម ទម្រង់នៃការចូលរួមក្នុងសហកម្មឧក្រិដ្ឋកម្មរួមគឺប្រាកដជាអាចមានខុសគ្នាយ៉ាងច្បាស់ក្រឡែត។ អ្នកជួយនិងជម្រុញក្នុងបទឧក្រិដ្ឋតែមួយ គាត់បានប្រព្រឹត្តក្នុងក្របខ័ណ្ឌនៃសហកម្មឧក្រិដ្ឋកម្មរួម គឺនៅតែចាត់ទុកថាជាអ្នកជួយ និងជម្រុញដល់សហកម្មឧក្រិដ្ឋកម្មរួមនោះបានដែរ លើកលែងតែ បទឧក្រិដ្ឋដែលដាច់តែឯងនេះពិតជាគ្មានជាប់ពាក់ព័ន្ធអ្វីបន្តិចសោះជាមួយនឹងសហកម្មឧក្រិដ្ឋកម្មរួមនោះ។ ចំពោះភាពខុសគ្នារវាងការប្រព្រឹត្តិរួម និងការជួយនិងជម្រុញ លក្ខណៈវិនិច្ឆ័យមួយដែលគួរឱ្យជឿទុកចិត្តថាអាចយកមកបកស្រាយបានគឺមានចែងក្នុងគោលការណ៍នៃការគ្របសង្កត់ជាក់ស្ដែងនៃអំពើនោះ (functional domination of the act) (*funktionelle Tatherrschaftslehere*) ដែលគេទទួលស្គាល់ជាទូទៅនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល (civil law system) និងថ្មីៗនេះត្រូវបានទទួលស្គាល់ដោយអង្គបុរេជំនុំជម្រះនៃតុលាការព្រហ្មទណ្ឌអន្តរជាតិផងដែរ[36]។ បើយោងតាមទ្រឹស្ដីនេះ ការប្រព្រឹត្តិរួម កំណត់បុរេលក្ខខណ្ឌនៃការសហប្រតិបត្តិការជាក់ស្ដែងនៃបុគ្គលនីមួយៗ (ធាតុផ្សំ

34

35

36

00238364

D99/3/27

សត្យានុម័តិ) ដោយផ្អែកលើមូលដ្ឋាននៃផែនការរួម ឬការព្រមព្រៀងគ្នារួមមួយ (ធាតុផ្សំអត្តនោម័តិ)[37] ។ ប្រសិនបើគេយកតាមទស្សនៈគ្រប់សង្កត់ជាក់ស្តែង (functional control concept) ដើម្បីបំពេញ**លក្ខខណ្ឌនៃការប្រព្រឹត្តិរួមទៅនេះបានគឺមានតែ** JCE I ប៉ុណ្ណោះ ហើយបំពេញបានទាល់តែគេរកឲ្យឃើញទៀតថាវាពិតជាបង្ហាញថាជា**រចនាសម្ព័ន្ធសត្យានុម័តិ-អត្តនោម័តិមួយ** ដែលតម្រូវឲ្យមានលើសពីគ្រាន់តែគោលបំណង ឬឆន្ទៈរួម (ធាតុផ្សំអត្តនោម័តិ) ពោលគឺការប្រព្រឹត្តិជាក់ស្តែងនៃអំពើនោះ (ទាំងនោះ) ដោយសមាជិកណាមួយនាក់ (ឬច្រើន) នៃសហកម្មឧក្រិដ្ឋកម្មរួមនោះ (ធាតុផ្សំសត្យានុម័តិ)។ មើលទៅទំនងដូចជា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ក្នុងរឿងក្តី ថាឌិច បានទទួលស្គាល់អត្តសញ្ញាណប្រភេទនេះ រវាងការប្រព្រឹត្តិរួម និង JCE I ដោយចាត់ទុក JCE I ថាជា "ការប្រព្រឹត្តិបទឧក្រិដ្ឋរួម (co-perpetratorship)[38]" និងបានប្រៀបធៀបវាទៅនឹងការប្រព្រឹត្តិរួមដូចដែលមាន លើកយកមកចោទសួរក្នុងករណីក្រោយសង្គ្រាមលោកលើកទី២ របស់ប្រទេសអាឡឺម៉ង់ និងអ៊ីតាលី[39]។ មើលទៅខាងយុត្តិសាស្ត្ររបស់ ICTY/ICTR ទំនងជាអនុវត្តតាមវិធីសាស្ត្រសត្យានុម័តិ-អត្តនោម័តិនេះ ក្នុងករណីដែលខ្លួនត្រូវរកឲ្យឃើញនូវភស្តុតាងសម្រាប់ JCE I ដែលថាអ្នកចូលរួម "បំពេញ" អំពើ "សត្យានុម័តិ" ដែលមានលក្ខណៈពាក់ព័ន្ធគ្នាដោយផ្ទាល់ទៅនឹងការជួយធ្វើឲ្យឆាប់បានសម្រេចនូវផែនការ ឬគោលបំណង(អត្តនោម័តិ)រួម"[40]។ ដូច្នេះ មើលទៅដូចជាត្រឹមត្រូវឲ្យយើងអាចទាញសេចក្តីសន្និដ្ឋានបានថា JCE I គឺជាទម្រង់មួយនៃការចូលរួម ដែលនៅក្នុងច្បាប់ស៊ីវិលគេហៅវាថាជាការប្រព្រឹត្តិរួម"[41] និងច្បាប់ common law[42] គេហៅវាថាជាគម្រោង/គោលបំណងរួម ឧទាហរណ៍ វាគឺជាទស្សនៈដាច់ដោយឡែក (sui generis) នៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដែលផ្អែកលើច្បាប់ស៊ីវិល និង common law[43]។

បញ្ហាដ៏លំបាកគឺថា តើអំពើ (សត្យានុម័ត) អ្វីខ្លះដែលចាំបាច់សម្រាប់ (JCE I)។ អង្គជំនុំជម្រះសាលាដំបូងលើករណីរបស់ ខ្វចក្កា បានលើកឡើងយ៉ាងត្រឹមត្រូវថា "ចំណុចដែលជាលក្ខខណ្ឌតម្រូវពិតប្រាកដនៃការចូលរួមនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមមិនទាន់បានបំពេញគ្រប់នៅឡើយ"[44]។ ដីកា

---

37

38

39

40

41

42

43

44

សម្រេចដ៏ល្បីល្បាញដែលចេញដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍ក្នុងករណី ថាឌិច ដែលត្រូវបាន អនុម័តិដោយយុត្តិសាស្ត្រភាគច្រើនជាបន្តបន្ទាប់ អនុលោមតាម "ការចូលរួម" នៅក្នុងគម្រោងរួម (សូមអាន JCE) "អាចមានទម្រង់ជាការជួយ ឬរួមវិភាគទានដល់ ការអនុវត្តផែនការ ឬគោលបំណងរួម"[45] ដីកានេះមានភាពស្រពិចស្រពិលខ្លឹមសាររវាងសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី១ ដែលត្រូវបានយល់ថា ជាការសហការជាមួយនឹងទម្រង់ផ្សេងទៀតនៃសហកម្មឧក្រិដ្ឋកម្មរួមជាពិសេស សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី៣។ ការប៉ុនប៉ងរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ក្នុងការញែកឱ្យដាច់ គ្នារវាងការប្រព្រឹត្តិរួម(សហចារីកម្ម) និងការជួយនិងជម្រុញ មិនអាចធ្វើទៅបាន ដោយហេតុថា អង្គជំនុំជម្រះលើកយក មកដោះស្រាយតែទំនាក់ទំនងរវាងអាទិចារី(អ្នកដែលប្រព្រឹត្តផ្ទាល់) និងអ្នក ជួយនិងជម្រុញនិងលក្ខខណ្ឌអត្តនោម័តនៃកិច្ចព្រមព្រៀង ដោយមិនគិតអំពីភាពខុសគ្នារវាងការរួម វិភាគទានជាសត្យានុម័តរបស់បុគ្គលដែលធ្វើអំពើដោយផ្អែកលើមូលដ្ឋាននៃគោលបំណងរួម (សូមអាន សហចារី) និងអ្នកដែលគ្រាន់តែជួយនិងជម្រុញនោះទេ។[46] តាមពិត ប្រសិនបើគេទទួលយកការញែក ញែកជាសត្យានុម័តរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ពិតប្រាកដមែននោះ អ្នកជួយនិងជម្រុញនឹងធ្វើ អំពើច្រើនជាងសហចារី៖ អ្នកជួយនិងជម្រុញធ្វើអំពើសំខាន់ៗ "ដែលតម្រង់ជាពិសេស" ទៅរកការ ជួយដល់ការប្រព្រឹត្តិនៃបទល្មើស(ដ៏សំខាន់) នៅពេលដែលសហចារីគ្រាន់តែអនុវត្តអំពើតែប៉ុណ្ណោះ (អំពើប្រភេទណាមួយក៏ដោយ) ដែល "តាមវិធីខ្លះ" បានជួយឆាប់ឱ្យបានសម្រេចគោលបំណង ឬ ផែនការរួម។[47] ចំណុចនេះ វាធ្វើឱ្យមើលឃើញនូវភាពខុសគ្នាជាប្រពៃណីរវាង ការប្រព្រឹត្តិរួម ជាមួយ នឹង ការជួយនិងជម្រុញ គឺថាភាពខុសគ្នាទាក់ទងនឹង ទម្ងន់នៃការរួមវិភាគទានដែលត្រូវតែធ្ងន់ជាងនៅ លើវានៅក្នុងករណីនៃការប្រព្រឹត្តិរួម។ វិធីតែមួយគត់ដើម្បីបង្ហាញថាការលើកទឡ្ហីករណ៍របស់អង្គជំនុំ ជម្រះមានអត្ថន័យគឺត្រូវធ្វើការបកស្រាយអំពីការរួមវិភាគទាននៃសមាជិកសមគំនិតនៃសហកម្មឧក្រិដ្ឋ កម្មរួមថាមានសារៈសំខាន់ច្រើនជាងការរួមវិភាគទាននៃការប្រព្រឹត្តិ(មិនមែនមួយផ្នែកនៃសហកម្ម ឧក្រិដ្ឋកម្មរួម) នៃបទល្មើសដ៏ជាក់លាក់ ដោយហេតុថាសមាជិកសមគំនិតបានរួមចំណែកដល់ "ហានិភ័យ" ឬ "គ្រោះថ្នាក់ជា ទូទៅ" ដែលមានចែងនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមនោះតែម្តង។ និយាយម្យ៉ាងទៀត សារៈសំខាន់នៃ ការរួមវិភាគទានផ្លាស់ប្តូរទៅតាមកម្មវត្ថុនៃការលើកឡើងថាវាជា

---

45

46

47

00238366

D99/3/27

បទល្មើសជាបុគ្គលឬជារួម។ ចំណុចគួរឲ្យចាប់អារម្មណ៍បំផុតនោះគឺថា សូម្បីតែអនុវត្តតាមការវែកញែករបស់សាលាឧទ្ធរណ៍ទាក់ទងនឹងករណី ថាឌិច ក៏ដោយ ក៏អង្គជំនុំជម្រះសាលាឧទ្ធរណ៍លើករណី វ៉ាស៊ីលចេវិច (*Vasiljević*) បានប្រកាន់ទស្សនៈនៅក្នុងកថាខណ្ឌតែមួយថា អ្នកចូលរួមនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម ត្រូវទទួលខុសត្រូវ ពីព្រោះសហចារីម្នាក់ត្រូវទទួលខុសត្រូវក្នុងកម្រិតខ្ពស់ជាងអ្នកជួយនិងជម្រុញ ដែលក្នុងករណីណាមួយក៏ដោយ ជានិច្ចជាអ្នកសមគំនិតជាមួយសហចារីនៃសហកម្មឧក្រិដ្ឋកម្មរួម។[48] នៅពេលដែលការពន្យល់នេះបានរៀបរាប់យ៉ាងត្រឹមត្រូវនូវភាពខុសគ្នារវាងការប្រព្រឹត្តិរួម ជាមួយនឹងការសមគំនិត វាមានភាពមិនច្បាស់លាស់ទាក់ទងនឹងទម្រង់សហកម្មឧក្រិដ្ឋកម្មរួម - ដែលមានតែ សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី១ ប៉ុណ្ណោះដែលតាមវិធានបានចែងអំពីការប្រព្រឹត្តិរួម- ហើយវាផ្ទុយទៅ នឹងជំហររបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍លើករណីថាឌិច ដែលតាមដែលយើងមើលឃើញបាន រួមចំណែកដល់ការដាក់ទម្ងន់ធ្ងន់ជាងទៅលើការរួមវិភាគទានដល់ការសមគំនិត។ តែ គេមិនអាចមាន ការវែកញែកនេះតាមវិធីទាំងពីរនោះបានទេ។ តាមទស្សនៈដ៏ត្រឹមត្រូវរបស់ខ្ញុំ ទាំងសហកម្មឧក្រិដ្ឋកម្ម រួមទម្រង់ទី១ ត្រូវបានធ្វើឲ្យស្មើជាមួយនឹងការប្រព្រឹត្តិរួម ហើយវិធានដែលពាក់ព័ន្ធអាចយកមកអនុវត្ត ជាពិសេសទាក់ទងនឹងការកំណត់ព្រំដែននៃការជួយនិងជម្រុញឬក៏ទម្រង់នៃការចូលរួមត្រូវបានទុកឲ្យនៅចំហក្នុងកម្រិតនៃការការសន្និត ហើយភាពខុសគ្នាត្រូវបានគេពិចារណាយ៉ាងល្អិតល្អន់បំផុតនៅឯ កម្រិតនៃការផ្តន្ទាទោស។[49]

## I.៤ សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី២ និងទី៣ ជា ទស្សនៈនៃការចោទប្រកាន់បែប (“ប្រព័ន្ធ) ស្វ័យតាព

ទាក់ទងនឹងការពិចារណាទាំងអស់នេះ ពេលនេះយើងអាចធ្វើការបែងចែក សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី២ និងទី៣ បានហើយ។ ចំពោះ សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី៣ វាហាក់ដូចជាច្បាស់ណាស់ថាការចោទប្រកាន់របស់វាអំពីអំពើមួយថាជា “ផលវិបាកដែលព្យាករដឹងមុន” ដែលមិនត្រូវបានយល់ស្របជាមុន ហើយដែលមិនមានចេតនាដោយអ្នកចូលរួមទាំងអស់ ការចោទប្រកាន់នេះអាចមានការពិបាកក្នុងការបង្កើតនូវទម្រង់នៃការប្រព្រឹត្តិរួម ឬការប្រព្រឹត្តតែឯងណាស់ ប្រសិនបើវាចាំបាច់

48

49

ដូចបានពន្យល់ខាងលើថា ចារីខ្លួនឯងបានបំពេញលក្ខណៈសម្បត្តិគ្រប់ធាតុផ្សំទាំងសត្យានុម័ត និង អត្តនោម័តនៃបទល្មើស។ ចំពោះនៅក្នុង សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី៣ វិញ ធាតុផ្សំមួយ ឬច្រើននៃ ធាតុផ្សំទាំងនេះមិនគ្រប់គ្រាន់ ហើយអាចត្រូវបានចោទប្រកាន់តែចំពោះសមាជិកនៃក្រុមតាមវិធី *ទទួលខុសត្រូវជំនួស (responsibilité du fait d'autrui)* គឺថា ដោយពឹងផ្អែកទៅលើ អំពើរបស់ ជនម្នាក់ផ្សេងទៀត ចារីដ៏ពិតប្រាកដ ដោយផ្លាស់ប្តូរអំពើនេះទៅជា "អ្នកមិនបានប្រព្រឹត្ត" ឬ "ការមិន បានប្រព្រឹត្ត" របស់សមាជិកនោះ។ ក៏ប៉ុន្តែ ការមិនប្រព្រឹត្តនេះ អាចត្រូវបានពិចារណាថាជាទម្រង់ នៃ **ការជួយនិងជម្រុញ** ដល់បទល្មើសនោះបាន។ បញ្ហានេះត្រូវបានបញ្ជាក់ដោយទ្រឹស្តីដែលជាប្រពៃណី អង់គ្លេសដែលចែងជាយូរមកហើយថា អ្នកចូលរួមនៅក្នុងគោលបំណងឧក្រិដ្ឋកម្មរួមមួយគឺជាអាទិចារី (តែ) *នៅក្នុងកម្រិតទី២* (ឧទាហរណ៍ អ្នកសមគំនិត) ពាក់ព័ន្ធទៅនឹងគ្រប់បទល្មើសដែលប្រព្រឹត្ត ដោយជនណាមួយនាក់នៃជនទាំងនេះនៅក្នុងការអនុវត្តន៍គោលបំណងនោះ។[50]

នៅក្នុងករណីនៃសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី២ ស្ថានភាពមានភាពស្មុគ្រស្មាញជាង ហើយវា អាស្រ័យលើការយល់ដឹងអំពីប្រភេទនេះ។ ប្រសិនបើគេអាចកំណត់លក្ខណៈរបស់សហកម្មឧក្រិដ្ឋកម្ម រួមទម្រង់ទី២ ថា "ទម្រង់ក្លាយ" ឬ ជាទម្រង់រងនៃសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី១[51] ដែលមាន លក្ខខណ្ឌតែមួយនោះវាពិតជាអាចយកមកគិតក្នុងបែបផែនតែមួយបាន។ ទោះយ៉ាងនេះក៏ដោយ ប្រសិនបើអនុវត្តតាមអង្គជំនុំជម្រះសាលាឧទ្ធរណ៍លើករណី ខ្មុចក្កា "ការរួមវិភាគទានសមល្មម" ដល់ ក្រុមគឺមិនចាំបាច់ត្រូវតែមាននោះទេ ដ្បិតអីគ្រាន់តែសមាជិកភាព និងភាពដឹងជាមុនតែប៉ុណ្ណោះ ក៏អាចបណ្តាលឲ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌបានផងដែរ។ ការដឹងទូលំទូលាយអំពីសហកម្ម ឧក្រិដ្ឋកម្មរួមទម្រង់ទី២បែបនេះគឺវាប្រហាក់ប្រហែលទៅនឹងសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី៣[52] ជា ជាងសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី១។ ដូចនេះហើយការយល់ដឹងបែបនេះមិនអាចត្រូវចាត់ទុកថាជា ការប្រព្រឹត្តិរួមមួយនោះទេ។ នៅក្នុងករណីនេះ សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី២ (ក្នុងន័យទូលាយ) ត្រូវតែបែងចែកជារចនាសម្ព័ន្ធ ដូចគ្នានឹងសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី២ដែរ គឺជាទម្រង់នៃការ ជួយនិងជម្រុញដល់ក្រុមឧក្រិដ្ឋកម្មមួយ ហើយបញ្ហាបន្ថែមបានកើតឡើងថាតើសហកម្មឧក្រិដ្ឋ

50

51

52

00238368

D99/3/27

កម្មរួមទម្រង់ទី២ និងទម្រង់ទី៣ មានចែង នៅក្នុងមាត្រា ៧(១)នៃលក្ខន្តិកៈ ICTY/មាត្រា ៦ (១)នៃលក្ខន្តិកៈ ICTR និងមាត្រា ២៥(៣) នៃ លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិដែរឬទេ។ ចំពោះមាត្រា ៧(១)នៃលក្ខន្តិកៈ ICTY/មាត្រា ៦ (១)នៃ លក្ខន្តិកៈ ICTR, សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី ២ និងទម្រង់ទី ៣ អាចដាក់បញ្ចូលនៅក្រោមរូបមន្ត "ជួយនិងជម្រុញ" ប្រសិនបើគេបកស្រាយ "ផ្ទុយមកវិញ"[53] ដូចដែលរាប់បញ្ចូលទៅក្នុងការសមគំនិតណាមួយនៅក្នុងការប្រព្រឹត្តរួម។ ក៏ប៉ុន្តែ ការជួយនិងជម្រុញដូចដែលបានយល់ដឹងនៅក្នុងលក្ខន្តិកៈ ICTY និង ICTR រួមទាំងមាត្រា ២៥(៣)(គ) នៃលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ វាខុសគ្នាលើផ្នែកគំនិតពី សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី ២ និងទម្រង់ទី ៣ ៖ ម្យ៉ាងវិញទៀត វាតម្រូវឲ្យមានការយល់ដឹង[54] ឬចេតនា (នៅក្នុងអត្ថន័យនៃមាត្រា ៣០ នៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ) និងនិយាយម្យ៉ាងទៀត ជាអំពើ "សម្រាប់គោលបំណងនៃការសម្របសម្រួលការប្រព្រឹត្តបទល្មើសបែបនេះ"។ ដូចនេះ ទម្រង់តែមួយគត់នៃការចូលរួមបើប្រៀបធៀបទៅនឹងសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី២ ឬទម្រង់ទី៣ វាគឺជាការទទួលខុសត្រូវរួមមួយដែលមានចែងនៅក្នុងមាត្រា ២៥(៣)(ឃ) នៃលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ។ តាមពិតអង្គជំនុំជម្រះសាលាឧទ្ធរណ៍លើករណី ថាឌិច បានពិចារណាថា ទម្រង់នៃការទទួលខុសត្រូវមាន "សញ្ញាណស្រដៀងគ្នាយ៉ាងខ្លាំង" ព្រមទាំងបាន "លើកស្ទួយ" គោលការណ៍សហកម្មឧក្រិដ្ឋកម្មរួម[55] ក៏ប៉ុន្តែទស្សនៈនេះមានការខ្វះខាតពីការបង្ហាញនូវភាពខុសគ្នារវាងប្រភេទទាំងឡាយនៃសហកម្មឧក្រិដ្ឋកម្មរួម ដែលបានចែងនៅក្នុងសេចក្តីសម្រេចនេះ។

នៅពេលដែលសហកម្មឧក្រិដ្ឋកម្មរួមទី ១ បង្កើតបានជាទម្រង់មួយនៃការប្រព្រឹត្តរួមនៅក្នុងអត្ថន័យនៃមាត្រា២៥(៣)(ក) 2nd alt. នៃលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី២ និងទម្រង់ទី៣ មិនត្រូវបានគេបញ្ចូលទៅក្នុងមាត្រា ២៥(៣)(ឃ) យ៉ាងហោចណាស់ក៏មានហេតុផល ២ យ៉ាងដែរ[56]។ ទី ១ អនុកថាខណ្ឌ ii នៃមាត្រា ២៥(៣)(ឃ) តម្រូវឲ្យមាន "ការយល់ដឹង" ពាក់ព័ន្ធនឹងចេតនាឧក្រិដ្ឋរបស់ក្រុម គឺថាជាងការគ្រាន់តែដឹងជាមុនដូចដែលកំណត់

53

54

55

56

ដោយសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី២ និងទម្រង់ទី៣។[57] ទី២ នៅពេលដែលគេ អាចលើកទឡ្ហីករណ៍ថាសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី២ និងទម្រង់ទី៣ ត្រូវបានគ្របដណ្ដប់ដោយមាត្រា ២៥(៣)(ឃ)(i) ដោយហេតុថាធាតុផ្សំស្ម័គ្រចិត្តនៃអនុកថាខណ្ឌនេះ ("គោលបំណងប្រព្រឹត្តសកម្មភាពឧក្រិដ្ឋបន្ថែមទៀត [...]") វាមិនត្រូវគ្នាជាមួយនឹងការព្យាករដឹងជាមុន[58] ក្នុងករណីណាមួយក៏ដោយការរួមវិភាគទានដល់បទល្មើសរួមត្រូវតែជា "ចេតនា" (មាត្រា ២៥ [៣][ឃ] 1st cl.) គឺថា តម្រូវឲ្យច្រើនជាងការគ្រាន់តែការព្យាករដឹងជាមុន។[59] លើសពីនេះ ដោយមានភាពស្រដៀងគ្នារវាងការទទួលខុសត្រូវដោយផ្អែកលើ សហកម្មឧក្រិដ្ឋកម្មរួមជាមួយនឹង ការសមគំនិត[60] ការបញ្ចូលការទទួលខុសត្រូវទៅក្នុងមាត្រា ២៥(៣)(ឃ) ដូចដែលបានគូសបញ្ជាក់ខាងលើ នឹងបញ្ច្រាសទៅនឹងបំណងប្រាថ្នារបស់អ្នកធ្វើសេចក្ដីព្រាងលក្ខន្តិកៈ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលអ្នកធ្វើសេចក្ដីព្រាងទាំងនោះបានបដិសេធការផ្សំគំនិតយ៉ាង ច្បាស់ ហើយបានធ្វើពង្រាងមាត្រា ២៥(៣)(ឃ) ឲ្យក្លាយជារូបមន្តសម្របសម្រួលមួយ។ យោងតាម ប្រវត្តិនេះមាត្រា ២៥(៣)(ឃ) អាចត្រូវបានគេចាត់ទុកយ៉ាងត្រឹមត្រូវថាជា "លក្ខន្តិកៈសម្របសម្រួល មួយនៃសហកម្មឧក្រិដ្ឋកម្មរួម"។[61] ចំពោះយុត្តិសាស្ត្រទៅអនាគតនៃ ICC នេះមានន័យថាការអនុវត្តន៍ JCE II (ក្នុងន័យទូលាយ) និង JCE III ដោយសំអាងលើមូលដ្ឋាននៃមាត្រា២៥ ហើយនេះគឺជាមូលដ្ឋានតែមួយគត់ដែលខ្លួនមាន គឺមិនអាចអនុវត្តទៅបានទេ[62]។ ការធ្វើដូច្នេះគឺចុងក្រោយមានន័យថាគឺជាការនាំយកអនុវត្តនូវច្បាប់នៃការសមគំនិតតាមរយៈទ្វារក្រោយ ពោលគឺគេមិនបានអើពើដល់ឆន្ទៈនៃអ្នកធ្វើសេចក្ដីព្រាងនៃសន្ធិសញ្ញាក្រុងរ៉ូម និង*បំពានគោលការណ៍និត្យានុកូលភាព*។ មានតែការកែច្បាប់ទៅជាក្រមឲ្យបានច្បាស់លាស់ប៉ុណ្ណោះដែលអាចសម្រួល JCE II និង JCE III ដើម្បីយកមកអនុវត្តឲ្យស៊ីគ្នា ទៅនឹងតម្រូវការនៃគោលការណ៍នេះបានសម្រាប់ការបង្កើតបញ្ញត្តិច្បាប់ព្រហ្មទណ្ឌដ៏តឹងរឹងមួយ (មាត្រា ២២[២] នៃលក្ខន្តិក ICC)[63]។ ឆ្លងតាមចំណុចទាំងអស់នេះ គេអាចសន្និដ្ឋានបានថា **JCE II និង JCE III គឺបង្កើតបានជាទស្សនៃការ**

---

57

58 ស

59

60

61

62

63

**ចោទប្រកាន់មួយដោយស្វ័យភាព (ជាប្រព័ន្ធ)** ដោយមិនចាំបាច់មានមូលដ្ឋានបញ្ជាក់ឱ្យបានច្បាស់ដូចក្នុងច្បាប់ ICL នោះទេ។

## ១.៥ ការពិចារណាជាពិសេស៖ JCE III និងគោលការណ៍នៃពិរុទ្ធភាព

គោលការណ៍នៃពិរុទ្ធភាពត្រូវបានគេទទួលស្គាល់ជាយូរមកហើយនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។ ជាទូទៅច្បាប់យុត្តិសាស្ត្របានទទួលស្គាល់ថាគោលការណ៍នៃពិរុទ្ធភាព (ជាលក្ខណៈបុគ្គល) ទាមទារឱ្យមានការយល់ដឹងរបស់ចុងចោទអំពីកាលៈទេសៈនៃបទល្មើស។ សាលាក្តីយោធាអន្តរជាតិនៅ Nuremberg បានយោងដល់គោលការណ៍នេះនៅក្នុងបរិបទនៃបញ្ហានៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អង្គការណាហ្ស៊ីខ្លះដោយគូសបញ្ជាក់ថា "គោលការណ៍ដ៏សំខាន់បំផុតមួយនៃបញ្ហាដ៏សំខាន់បំផុតទាំងឡាយ (គោលការណ៍ច្បាប់) ... គឺថា ពិរុទ្ធភាពព្រហ្មទណ្ឌមានលក្ខណៈជាបុគ្គល ហើយថាការដាក់ទណ្ឌកម្មដ៏ធ្ងន់ធ្ងរគួរត្រូវចៀសវាង" ហើយថា "សាលាក្តីគួរតែធ្វើសេចក្តីប្រកាសបែបនេះអំពីភាពជាប់ចោទពីបទឧក្រិដ្ឋ (របស់អង្គការមួយឬក្រុមមួយ) ឱ្យបានច្បាស់តាមដែលអាចធ្វើទៅបាននៅក្នុងទម្រង់មួយដើម្បីធានាថាជនគ្មានពិរុទ្ធនឹងមិនត្រូវបានគេដាក់ទោស"។[64]

នៅក្នុងទស្សនាទាននៃសាលាក្តីយោធាអន្តរជាតិអំពី "ពិរុទ្ធភាពជាបុគ្គល" ដែលមានន័យថា ជនជាប់ចោទនឹងទទួលខុសត្រូវជាបុគ្គលនៅក្នុងពាក្យសត្យានុម័ត និងអត្តនោម័ត និងថាគ្មានមេធាវីការពារក្តីណាម្នាក់នឹងបដិសេធការទទួលខុសត្រូវរបស់ខ្លួនបានឡើយ។ នៅក្នុងការជំនុំជម្រះជាបន្តបន្ទាប់ មានការលើកឡើងដដែលៗជាញឹកញាប់ថា ការទទួលខុសត្រូវជាបុគ្គលសន្មតទុកជាមុនថាជាពិរុទ្ធភាពបុគ្គល។[65] ដូចគ្នានេះដែរអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៅ ICTY បានទទួលស្គាល់គោលការណ៍នៃពិរុទ្ធភាពនៅក្នុងករណី ថាឌិច ដោយគូសបញ្ជាក់ថា "គ្មាននរណាម្នាក់អាចទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើទាំងឡាយ ឬការប្រព្រឹត្តដែលជននោះមិនមានការពាក់ព័ន្ធជាបុគ្គល ឬនៅក្នុងវិធីផ្សេងទៀតដែលបានចូលរួម (*nulla poena sine culpa*)"។[66] ទោះបីគោលការណ៍នេះមិនមានចែងយ៉ាងច្បាស់នៅក្នុងលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិក៏ដោយ ក៏គោលការណ៍នេះបានដើរតាមលំអាន

64
65
66

00238371

D99/3/27

ច្បាប់ដែលមានជាធរមានយ៉ាងប្រត្យ័ក្សទាំងតាមយុត្តិសាស្ត្រនាពេលខាងមុខ - ជាគោលការណ៍ និងវិធាននៃច្បាប់អន្តរជាតិនៅក្នុងអត្ថន័យនៃមាត្រា ២១(១)(ខ) នៃលក្ខន្តិកៈ ទាំងជាគោលការណ៍ទូទៅនៃច្បាប់ នៅក្នុងអត្ថន័យនៃមាត្រា ២១(១)(គ) នៃលក្ខន្តិកៈ។ នៅក្រោមច្បាប់ អ.វ.ត.ក គោលការណ៍នេះត្រូវបានគេទទួលស្គាល់ជាផ្នែកមួយនៃគោលការណ៍ជំនុំជម្រះដ៏ត្រឹមត្រូវដែលមានចែងនៅក្នុងមាត្រា ៣៣ ថ្មី និងជាផ្នែកផ្សេង (ដ៏សំខាន់) នៃសច្ចធារនិរទោស (មាត្រា ៣៥ថ្មី [១])។

វាជាក់ច្បាស់ខ្លាំងណាស់ដែលថា សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី៣ មិនចុះសម្រុងគ្នាជាមួយគោលការណ៍នៃពិរុទ្ធភាព។ អនុលោមតាមសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី៣ ប្រសិនបើសមាជិកទាំងអស់នៃក្រុមឧក្រិដ្ឋកម្មទទួលខុសត្រូវព្រហ្មទណ្ឌ សូម្បីអំពើឧក្រិដ្ឋដោយសមាជិកខ្លះដែលមិនបានយល់ស្របដោយសមាជិកទាំងអស់មុនការប្រព្រឹត្តដ៏ជាក់លាក់ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ វាត្រូវបានចាត់ទុកថាមានការពាក់ព័ន្ធចំពោះសមាជិកទាំងអស់ដោយផ្អែកលើមូលដ្ឋាននៃការដឹងជាមុន ការព្រមព្រៀងជាមុន ឬផែនការរបស់អ្នកចូលរួមជា មូលដ្ឋាននៃការសន្មតអញ្ញមញ្ញ។ ដូចនេះ គោលការណ៍ជាទូទៅមួយនៅក្នុងច្បាប់នៃការប្រព្រឹត្តរួមត្រូវបានគេលុបចោល។[67] អត្ថិភាពនៃទំនាក់ទំនងហេតុផលរវាងការព្រមព្រៀង ឬផែនការដំបូង និងភាពលើសលប់នៃឧក្រិដ្ឋភាព មិនអាចលប់លើភាពមិនគ្រប់គ្រាន់នៃភាពគួរដាក់ទណ្ឌកម្មបានទេ[68]។ លើសពីនេះ បទដ្ឋាននៃការព្យាករដឹងជាមុនមិនមានភាពជាក់ស្តែង ថែមទាំងមិនអាចទុកចិត្តបានទៀតផង[69]។ អ្វីដែលគួរឲ្យហួសចិត្តនោះគឺថា មនុស្សម្នាក់អាចនិយាយថា បទដ្ឋាននៃការដឹងជាមុនដែលអនុវត្តតាមវិធីនេះ នឹងធ្វើឲ្យការដាក់ទណ្ឌកម្មចំពោះជនជាប់ចោទក្លាយជាការមិនដឹងជាមុនទៅវិញ។ ចំពោះហេតុផលនេះ -ភាពមិនប្រាកដប្រជានៃបទដ្ឋាននៃការដឹងជាមុន- មនុស្សម្នាក់មិនអាចទិតៀនសមាជិកនៃសហកម្មឧក្រិដ្ឋកម្មរួមថាមិនបានដកខ្លួនថយចេញពីក្រុមឧក្រិដ្ឋ៖ ហេតុដូចម្តេច និងហេតុអ្វីបានជាជននោះត្រូវធ្វើបែបនោះ ប្រសិនបើរូបគេមិនទាំងបានដឹងជាមុនអំពីលទ្ធផលនៃបទល្មើសនោះប្រាកដថាដូចម្តេចផងនោះ?[70] ជាអវសាន្តទ្រឹស្តីតម្រូវឲ្យអនុវត្តទម្រង់នៃការទទួលខុសត្រូវដ៏តឹងរឹងជាមួយបទដ្ឋាននេះ។[71]

---

67

68

69

70

71

00238372

D99/3/27

តាមទស្សនៈរបស់មេធាវីការពារក្តី នៅពេលដែលនេះអាចគ្រាន់តែជាហេតុផលសម្រាប់ភាពទាក់ទាញនៃទ្រឹស្តីនោះដើម្បីសម្រាប់តែការចោទប្រកាន់ ដូចជាលទ្ធភាពនៃការដោះស្រាយបញ្ហាឱ្យល្អមើលនៅក្នុងស៊ីណារីយ៉ូឧក្រិដ្ឋនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ជាពិសេសនៅពេលដែលខ្វះភស្តុតាងនៃការចូលរួមដោយផ្ទាល់[72] វាបង្ហាញថា នេះជាគុណវិបត្តិដ៏ធំបំផុតរបស់ទ្រឹស្តីនេះ ។

ចៅក្រមខ្លះក៏ហាក់ដូចជាមានបញ្ហាជាមួយបទដ្ឋាននៃ*ការដឹងជាមុន*។ ចៅក្រមថែមទាំងបានបន្ទាបការប្រព្រឹត្តិនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមមួយមកត្រឹមការជួយនិងជម្រុញ (ជាសហកម្មឧក្រិដ្ឋកម្មរួមមួយឬជាបទល្មើសតែមួយ)[73] ឬព្យាយាមបង្កើន ឬកែប្រែកម្រិតកំណត់អត្តនោម័ត ដោយតម្រូវឱ្យមានទាំងការយល់ដឹងរួម និងការដឹងជាមុន។ យោងតាមអង្គជំនុំជម្រះសាលាឧទ្ធរណ៍ "បញ្ហានេះត្រូវតែធ្វើការវាយតម្លៃពាក់ព័ន្ធនឹងការយល់ដឹងរបស់ជនជាប់ចោទដ៏ជាក់លាក់ម្នាក់"។ ព្រះរាជអាជ្ញាត្រូវបង្ហាញថា "ជនជាប់ចោទមានការយល់ដឹងគ្រប់គ្រាន់ ហើយមានការយល់ដឹងទៀតថាបទល្មើសផ្សេងទៀតវាបង្កផលវិបាកជាធម្មតា និងដែលអាចដឹងជាមុនបានចំពោះជននោះ"។[74] នៅពេលដែលការយល់ដឹងមានសារៈសំខាន់ជាងគេនៅក្នុងបទដ្ឋាននៃការធ្វេសប្រហែសក្នុងករណី ថាឌិច *(Tadic dolus eventualis)*[75] ទំនាក់ទំនងរវាងការយល់ដឹង ជាមួយនឹងការដឹងជាមុនវាមានច្បាស់លាស់ណាស់ទោះជាតាមមធ្យោបាយណាក៏ដោយ។ ប្រសិនបើ នរណាម្នាក់ផ្តល់និយមន័យអត្តនោម័តដល់បទដ្ឋានទាំងពីរ គឺថាដោយលើកពីចេនាទុច្ចរិតនៃអ្នកចូលរួមដ៏ពិតប្រាកដម្នាក់ដែលជននោះទទួលខុសត្រូវចំពោះអំពើទាំងឡាយហួសពីវិសាលភាពនៃក្រុមនោះការរួមផ្សំនៃបទដ្ឋានទាំងពីរទំនងជាអាចធ្វើឱ្យរង្វង់មួយក្លាយជារាងការេបាន។ ទោះបីជនជាប់ចោទបានដឹងថា លទ្ធផលខ្លះនឹងកើតឡើង ឬលទ្ធផលនេះអាចដឹងជាមុន ចំពោះជននេះក៏ដោយ ការយល់ដឹងពីផលវិបាកទាំងពីរនេះមិនអាចទៅរួចជាពិតប្រាកដនោះទេ។ តាមពិត ការយល់ដឹងគឺជាបទដ្ឋានមួយនៃបទល្មើសដែលមានចេតនា (សូមអានមាត្រា ៣០ លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ) នៅពេលដែលការដឹងជាមុនគឺជាទ្រឹស្តីនៃភាពធ្វេសប្រហែស ឬសេចក្តីប្រមាទ។ វិធីតែមួយដើម្បីចាកចេញពីស្ថានភាពទ័លច្រកនេះ គឺត្រូវបកស្រាយការដឹងជាមុនថាជាលក្ខខណ្ឌជាសត្យានុម័តមួយ (ក្នុងអត្ថន័យនៃបទដ្ឋាននៃជនទទួលខុសត្រូវចំពោះ

---

72

73

74

75

អំពើឃោរឃៅ) ដោយទុកបទដ្ឋាននៃការយល់ដឹងថា (គ្រាន់តែ) ជាលក្ខខណ្ឌអត្តនោម័ត ឬផ្លូវចិត្តនៃការទទួលខុសត្រូវ។[76] ជាក់ស្តែងណាស់ ការធ្វើបែបនេះនឹងធ្វើឱ្យមេធាវីការពារក្តីមានការលំបាកជាងមុន ដោយហេតុថា វាមានការងាយស្រួលក្នុងការចោទប្រកាន់ និង/ឬ វិនិច្ឆ័យដើម្បីចោទប្រកាន់ថា "ជនដែលអាចរងការចោទប្រកាន់" នេះបានដឹងជាមុនអំពីលទ្ធផលនៃបទល្មើស បើវាមិនអាចអនុវត្តបានទេនោះ វាក៏បង្ករការពិបាកចំពោះមេធាវីការពារក្តីមិនឱ្យបដិសេធនូវអំណះអំណាងនេះដែរ។ ជាលទ្ធផល ការទទួលខុសត្រូវចំពោះ សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ បានសន្មតជាមុនថា ជាដំបូងការដឹងជាមុនជាសត្យានុម័តនៃបទល្មើសដែលហួសគោលបំណងរបស់ក្រុម (ដោយហេតុថា បទល្មើសបែបនោះកើតឡើងនៅក្នុងបរិបទធម្មតានៃព្រឹត្តិការណ៍ដែលប្រព្រឹត្តដោយក្រុម) ហើយទី២ ការយល់ដឹងពីអ្នកចូលរួមដ៏ពិតប្រាកដ ពាក់ព័ន្ធនឹងការដឹងជាមុន (សត្យានុម័ត) នេះ។[77] និយាយឱ្យងាយយល់ជាងនេះគឺថា៖ អ្នកចូលរួមត្រូវដឹងថា បទល្មើសដែលមានបញ្ហាជាធម្មតាកើតឡើងនៅក្នុងក្រុមដ៏ពិតប្រាកដមួយ។ ក៏ប៉ុន្តែ នៅពេលដែលការបកស្រាយនេះអាចត្រឹមត្រូវទាក់ទងនឹងការរួមផ្សំមិនប្រាកដប្រជានៃការយល់ដឹង និងការដឹងជាមុនវាអាចនាំឱ្យសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ ធ្លាក់ចូលទៅក្នុងគោលការណ៍នៃពិរុទ្ធភាព។ បើបែបនេះ វាមិនអាចជួយនៅក្នុងរឿងទាំងឡាយដែលជនជាប់ចោទយកលេសថា ខ្លួនខ្វះការយល់ដឹងទាក់ទងនឹងការដឹងជាមុន គឺថា ជននោះអាចយកលេសថា ខ្លួនមានជម្ងឺផ្លូវចិត្ត និងមិនបានដឹងពីការដឹងជាមុនដែលបានបកស្រាយតាមបទដ្ឋាននៃបទល្មើសដ៏ធ្ងន់ធ្ងរនេះ។ ក្នុងករណីនេះ ជននេះអាចប្រព្រឹត្តខុស ឬធ្វើខុស ពេលនោះមានសំណួរលើកឡើងថា តើវាជាកំហុសប្រភេទអ្វី- តើគាត់ប្រព្រឹត្តខុសទាក់ទងនឹងអង្គហេតុ ឬអង្គច្បាប់ ហើយតើកំហុសនេះវានឹងស្តែងចេញនូវផលវិបាកអ្វីខ្លះ។ ពិតប្រាកដណាស់ ឧបាស្រ័យចំពោះ ទ្រឹស្តីដ៏ស្មុគស្មាញនៃកំហុសរបស់ច្បាប់នឹងមិនចាំបាច់ ប្រសិនបើនរណាម្នាក់ត្រូវពិចារណានូវទស្សនាទានដ៏ជាក់ស្តែងមុន ព្រឹត្តិការណ៍ (*ex ante)* របស់ជនជាប់ចោទដ៏ពិតប្រាកដជាជាងដាក់ឱ្យជននេះ ស្ថិតនៅក្រោមបទដ្ឋានដែលជននេះអាចរងការចោទប្រកាន់។

76

77

និទ្ទាការផ្ទុយនោះគឺ ការពន្លាតបទដ្ឋាននៃការដឹងជាមុនទៅដល់ *បទល្មើសដែលមានចេតនាជាក់លាក់* ហើយនេះវាស្រដៀងទៅនឹងប្រល័យពូជសាសន៍។ អង្គជំនុំជម្រះ សាលាឧទ្ធរណ៍លើករណី *Brdanin*[78] បានបន្ទាបចេតនាដ៏ជាក់លាក់នៃប្រល័យពូជសាសន៍នៅក្នុងករណីនៃ សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ មួយមកត្រឹមតែការដឹងជាមុន ដោយរំលងលក្ខខណ្ឌនៃចេតនាដ៏ជាក់លាក់ និងដោយជំនះបញ្ហាដែលទាក់ទងនឹងបញ្ហាភ័ស្តុតាងដែលគេដឹងឮគ្រប់គ្នានេះ។ អង្គជំនុំជម្រះលើករណី *Milosevic* គ្រាន់តែអនុវត្តតាមវិធីសាស្ត្រនេះប៉ុណ្ណោះ។[79] ក៏ប៉ុន្តែ វិធីសាស្ត្រនេះត្រូវបានចែងនៅក្នុងយុត្តិសាស្ត្រច្បាប់។ ខុសពីអង្គជំនុំជម្រះសាលាឧទ្ធរណ៍ អង្គជំនុំជម្រះអំពីវិធាន ៩៨លើករណី *Stakic* និង *Brdanin* បានប្រកាន់ជំហរថា ចេតនា (ប្រល័យពូជសាសន៍) ដ៏ជាក់លាក់ត្រូវតែបំពេញ។[80] លើសពីនេះនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ *Krstic* លើកក្រោយ ការទទួលខុសត្រូវលើ សហកម្មឧក្រិដ្ឋកម្មរួមរបស់ជនជាប់ចោទ ចំពោះការសម្លាប់បែបប្រល័យពូជសាន៍នៅក្នុង Srebrenica ត្រូវបានបដិសេធពីព្រោះតែខ្វះចេតនាប្រល័យពូជសាសន៍[81] ហើយ សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី៣ មិនអាចដោះស្រាយបញ្ហាចេតនាឧក្រិដ្ឋនេះបានទេ។

## ១.៦ លទ្ធផលផ្សេងៗ

លទ្ធផលដែលចេញមកពីការពិចារណាខាងលើអាចសង្ខេបដូចតទៅ៖

១. សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី ១ ដូចគ្នានឹងចារីកម្មដែលជាប្រពៃណី ដោយហេតុថា អ្នកចូលរួមប្រព្រឹត្តដោយផ្អែកលើមូលដ្ឋាននៃផែនការរួម ("ការរៀបចំគម្រោងរួម" ឬ "ក្រុមរួម")។ ប្រសិនបើនរណាម្នាក់ បកស្រាយ សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី ១ ថា វាមានធាតុផ្សំសត្យានុម័ត និងអត្តនោម័ត នៅក្នុងអត្ថន័យនៃទស្សនទាននៃការត្រួតត្រាជាក់ស្តែង វាអាចត្រូវបានគេចាត់ទុកថាជា **ទម្រង់នៃការប្រព្រឹត្ត** អនុលោមតាមមាត្រា ៧(១) នៃលក្ខន្តិកៈ ICTY/មាត្រា ៦(១) នៃលក្ខន្តិកៈ ICTR។ ២. សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី ២ អាចចាត់ទុកថាជា អនុប្រភេទនៃ សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី ១ ប្រសិនបើវាត្រូវបានគេបកស្រាយយ៉ាងចង្អៀតមែននោះ។ នៅក្នុងអត្ថន័យដ៏ទូលំទូលាយមួយនៃការពន្លាតការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី ២ មានលក្ខណៈដូចគ្នានឹង សហកម្មឧក្រិដ្ឋ

78

79

80

81

00238375

D99/3/27

កម្មរួមទម្រង់ទី ៣ ជាង ដូចនេះចំណុចខាងក្រោមនេះអាចអនុវត្តបាន។[82] ៣. សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ មិនអាចត្រូវបានគេចាត់ទុកថាជាទម្រង់មួយនៃការប្រព្រឹត្តិរួមក៏ប៉ុន្តែត្រឹមតែជាទម្រង់មួយនៃ**ការជួយនិងជម្រុញ**ក្រុមឧក្រិដ្ឋ។ សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី ២ គឺជាទស្សនាទានស្វ័យយ័តមួយនៃការចោទប្រកាន់ដែលមិនបានបង្កើតជាទម្រង់នៃប្រព្រឹត្តដូចនៅក្នុងអត្ថន័យនៃមាត្រា ៧(១) នៃលក្ខន្តិកៈ ICTY/មាត្រា ៦(១) នៃលក្ខន្តិកៈ ICTR ទេ។ តាមពិត សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ បានបង្ហាញយ៉ាងច្បាស់បំផុតនូវភាពស្រដៀងគ្នានៃគោលការណ៍សហកម្មឧក្រិដ្ឋកម្មរួមទៅនឹងការ ទទួលខុសត្រូវនៃការសមគំនិតជាទូទៅ ដោយហេតុថា វាធ្វើឱ្យអ្នកចូលរួមម្នាក់នៅក្នុងក្រុមឧក្រិដ្ឋមួយទទួលខុសត្រូវសូម្បីតែបទល្មើសរបស់អ្នកចូលរួមដទៃទៀតដែលមិនត្រូវបានយល់ស្របយ៉ាងច្បាស់ពីមុន ក្នុងករណីដែលបទឧក្រិដ្ឋនោះគេអាចព្យាករដឹងមុនបាន។ ដូចនេះ ការទទួលខុសត្រូវវាផ្អែកជាពិសេសលើសមាជិកភាពនៅក្នុងក្រុមដែលអនុវត្តសហកម្មឧក្រិដ្ឋកម្មរួម ហេតុដូច្នេះ វាមិនស្របគ្នាជាមួយនឹងគោលការណ៍នៃពិរុទ្ធភាពនោះឡើយ។

## ភាគ ២. ការអនុវត្តនៅចំពោះមុខ អ.វ.ត.ក

### II.១ ការសាកល្បងដែលអាចយកមកអនុវត្តបាន៖ និត្យានុកូលភាពជាគោលការណ៍ក្នុង ICL

មាត្រា ៣៣ ថ្មី(២) បានលើកយកមាត្រា ១៥ នៃ ICCPR ដូចនេះហើយវាបានបញ្ចូលជាផ្នែកមួយនៃគោលការណ៍នីត្យានុកូលភាព (*nullum crimen nulla poena sine lege)* នៃប្រព័ន្ធច្បាប់របស់ អ.វ.ត.ក។ តាមន័យនេះ "(គ្មាន) នរណាម្នាក់ជាប់ពិរុទ្ធភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយដោយសារមូលហេតុនៃអំពើឬការមិនប្រព្រឹត្តណាមួយដែលមិនបានបង្កើតជាបទល្មើសព្រហ្មទណ្ឌនៅក្រោមច្បាប់ជាតិ ឬអន្តរជាតិ នៅចំពេលដែលអំពើនោះបានប្រព្រឹត្តនោះទេ"។ (មាត្រា ១៥[១] ICCPR)។ ចំពោះបទល្មើសដែលបានប្រព្រឹត្តនៅក្នុងប្រទេសកម្ពុជារវាងឆ្នាំ ១៩៧៥ និង ១៩៧៩ នេះមានន័យថា យុត្តាធិការរបស់ អ.វ.ត.ក អាចគ្របដណ្តប់លើបទល្មើសទាំងនេះបាន ល្គឹកណាតែបទល្មើសទាំងនេះបង្កើតបានជាបទល្មើសព្រហ្មទណ្ឌ (អន្តរជាតិ ឬជាតិ) នៅពេលដែលបទឧក្រិដ្ឋនោះត្រូវបានប្រព្រឹត្ត។ គោលការណ៍នៃនីត្យានុកូលភាពក៏អនុវត្តចំពោះ *វិធាននៃការចោទប្រកាន់* ផងដែរ ឧទាហរណ៍

82

00238376

D99/3/27

សហកម្មឧក្រិដ្ឋកម្មរួម ដោយហេតុថា វិធានទាំងនេះផ្សាភ្ជាប់ទៅនឹងការប្រព្រឹត្តិជាបុគ្គលជាមួយនឹងបទល្មើស ហេតុដូច្នេះហើយ ត្រូវបានចាត់ទុកថាជាមូលដ្ឋានសម្រាប់ការទទួលខុសត្រូវព្រហ្មទណ្ឌ។

នៅពេលដែលនីត្យានុកូលភាព គឺជាគោលការណ៍សិទ្ធិមនុស្សមួយ ដូចដែលមានចែងនៅក្នុង មាត្រា ១៥(១) នៃ ICCPR ទំនងជាត្រូវបានកំហិតចំពោះការហាមឃាត់ចំពោះច្បាប់ដាក់ទោសផ្នែកព្រហ្មទណ្ឌជាប្រតិសកម្ម (*ex post facto*) នៅក្នុង*តុលាការព្រហ្មទណ្ឌអន្តរជាតិ* សម័យទំនើប ដោយផ្អែកលើមូលដ្ឋាននៃគោលការណ៍ជាទូទៅនៃច្បាប់ និងជាសមាសធាតុជាមូលដ្ឋានរបស់ច្បាប់ មិនត្រឹមតែវិធាននៃការគ្មានប្រតិសកម្ម (*lex praevia)* ប៉ុណ្ណោះទេ តែមានវិធាននៃគោលការណ៍ប្រាកដប្រជា (*lex certa)* ផងដែរ។[83] ចំពោះវិធាននៃគោលការណ៍តឹងរឹង (*lex stricta) វិញគឺ* ស្ថានការណ៍មិនសូវជាច្បាស់ ប៉ុន្មាននោះទេ។ គេអាចចាត់ទុកថាវាសមមូលទៅនឹងវិធាននៃការអនុវត្តន៍តឹងរឹងឬបកស្រាយទៅតាមអ្វីដែលជាអត្ថបទសំណេររបស់ច្បាប់[84] ដូចដែលបានបង្កើតក្នុងច្បាប់អង់គ្លេសដូច្នេះដែរ។[85] អាស្រ័យហេតុនេះ ចៅក្រមតម្រូវឲ្យធ្វើការបកស្រាយច្បាប់ព្រហ្មទណ្ឌយ៉ាងតឹងរឹង ដ្បិតក្នុងករណីមានវិមតិសង្ស័យ ផលប្រយោជន៍គឺបានទៅខាងភាគីចុងចោទ។ ក៏ប៉ុន្តែប្រសិនបើគេយល់ពីលក្ខខណ្ឌនៃគោលការណ៍តឹងរឹងនេះនៅក្នុងត្រឹមតែបកស្រាយតាមន័យធៀប ដែលត្រូវបានហាមឃាត់តាមគោលការណ៍បកស្រាយយកតែខាងអាក្រក់ (*malam partem)* វាមានការពិបាកក្នុងការអនុវត្តលក្ខខណ្ឌ នេះនៅក្នុងយុត្តិសាស្ត្រច្បាប់រួម (ជាប្រពៃណី) ដោយហេតុថា ការបកស្រាយតាមសទិសន័យមិនត្រូវបានហាមឃាត់ ក៏ប៉ុន្តែត្រូវបានចាត់ទុកថា ជាផ្នែកមួយនៃដំណើរការរកឃើញនៃការបង្កើតច្បាប់នៃតុលាការ[86] - ដរាបណាការបង្កើតច្បាប់តុលាការនៅតែត្រូវបានគេទទួល (ជាប្រព័ន្ធច្បាប់មួយនៃ ចក្រភពអង់គ្លេស)។ មាត្រា ២២ ដល់ ២៤ នៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិបានទៅ ហួសពីការអភិវឌ្ឍទាំងនេះ ដោយហេតុថា មាត្រាទាំងនេះបានផ្តល់នូវទស្សនាទានដ៏ទូលំទូលាយអំពី គោលការណ៍នៃការគ្មានបទល្មើស (*mullum crimen)* ដែលរួមមានធាតុផ្សំទាំង ៤ របស់វាដែលត្រូវបានទទួលស្គាល់ជាទូទៅនៅក្នុងយុត្តាធិការច្បាប់រដ្ឋប្បវេណី៖ វិធានការគ្មានប្រតិសកម្ម (*lex*

83
84
85
86

*praevia), វិធាននៃគោលការណ៍ប្រាកដប្រជា (lex certa), វិធានតឹងរឹង (lex stricta)* និង *lex scripta* ។

នៅក្នុងគ្រប់ករណីណាក៏ដោយ ចំពោះសំណុំរឿងដែលកំពុងចាត់ការ សារៈសំខាន់នៃបញ្ហាគឺថា តើការអនុវត្តន៍សហកម្មឧក្រិដ្ឋកម្មរួមនឹងរំលោភវិធាន *lex praevia* ឬមួយយ៉ាងណា គឺថាតើមានទម្រង់នៃការទទួលខុសត្រូវឬទេនៅពេលដែលមានការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា ឬអន្តរជាតិនោះ។ ចំពោះគោលបំណងរបស់យើង ការសាកល្បងនេះត្រូវបានបែងចែក ដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍លើករណី Milutinovic[87] ទៅជាលក្ខខណ្ឌតូចៗ ៣ ដែលអាចបង្កើតឡើងវិញដូចខាងក្រោម៖

- មានសហកម្មឧក្រិដ្ឋកម្មរួមនៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅពេលវេលាសមស្រប (សូមមើលខាងក្រោម ត្រង់ចំណុច II.3.) ឬ
- មានសហកម្មឧក្រិដ្ឋកម្មរួមនៅក្នុងច្បាប់ជាតិនៅពេលវេលាដែលពាក់ព័ន្ធនោះ (II.4) និង
- ទម្រង់នៃការទទួលខុសត្រូវនេះប្រាកដជាបានដឹងមុន និងអាចប្រមើលដឹងជាមុនចំពោះចុងចោទនៅពេលវេលាដែលពាក់ព័ន្ធនោះ (II.5.)។

ទោះបីជាយ៉ាងណាក៏ដោយ ការអនុវត្តស្របតាមលក្ខខណ្ឌទាំងនេះវាមិនគ្រប់គ្រាន់ ដោយហេតុថាការទទួលខុសត្រូវនេះក៏ត្រូវតែមានចែងនៅក្នុងច្បាប់ (អ.វ.ត.ក) ដែលមានជាធរមានផងដែរ។[88] តាមពិត នេះគឺជាសំណួរដំបូងដែលត្រូវឆ្លើយដូចតទៅនេះ៖

## II. ២. តើការទទួលខុសត្រូវរបស់សហកម្មឧក្រិដ្ឋកម្មរួមត្រូវបានគេចែងក្នុងច្បាប់របស់ អ.វ.ត.ក ដែរឬទេ?

បទប្បញ្ញត្តិដ៏ខ្លីរបស់ច្បាប់ អ.វ.ត.ក អំពីការទទួលខុសត្រូវបទឧក្រិដ្ឋរបស់បុគ្គល មាត្រា ២៩ បានចែងនៅក្នុងកថាខណ្ឌទី១ថា "ជនសង្ស័យណាដែលបានរៀបចំផែនការ ញុះញង់ បញ្ជា ជួយនិងជម្រុញ ឬបានប្រព្រឹត្តឧក្រិដ្ឋកម្ម" ស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក "ត្រូវមានការទទួលខុសត្រូវជា លក្ខណៈបុគ្គល"។ បទប្បញ្ញត្តិនេះស្រដៀងគ្នាទៅនឹងមាត្រា ៧(១) នៃលក្ខន្តិកៈតុលាការ ICTY

87

88

និងមាត្រា ៦(១) នៃលក្ខន្តិកៈតុលាការ ICTR ។ ដូច្នេះ ដំបូងយើងអាចយោង ទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ជាសំខាន់ស្តីអំពីការបកស្រាយបទប្បញ្ញត្តិនេះ ជាពិសេសពាក្យថាបានប្រព្រឹត្ត។ ទោះបីជាយ៉ាងណាក៏ដោយ សាលក្រមនេះមិនមានលក្ខណៈច្បាស់លាស់ ចំពោះថាតើការចូលរួមនៅក្នុងឧក្រិដ្ឋកម្មមួយតាមវិធីនៃសហកម្មឧក្រិដ្ឋកម្មរួម ត្រូវបានក្តោបន័យដោយពាក្យថា "បានប្រព្រឹត្ត" ឬយ៉ាងណា នៅក្នុងមាត្រា ៧(១) នៃលក្ខន្តិកៈ តុលាការ ICTY ។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះយល់ឃើញថា "ការប្រព្រឹត្តិឧក្រិដ្ឋកម្ម (...) អាចកើតឡើងផងដែរតាមរយៈការចូលរួមនៅក្នុងការដឹងជាមុននូវគោលបំណង និងគម្រោងរួម" ហើយមាត្រា ៧(១) "មិនបានដកចេញនូវប្រភេទនៃការចូលរួមទាំងនោះក្នុងការ ប្រព្រឹត្តឧក្រិដ្ឋកម្មដែលកើតឡើង នៅពេលដែលមនុស្សជាច្រើនដែលមានគោលបំណងរួមមួយចាប់ផ្តើមសកម្មភាពឧក្រិដ្ឋកម្មដែលបន្ទាប់មកត្រូវបានអនុវត្តរួមគ្នា ឬដោយសមាជិកខ្លះនៃចំនួនមនុស្សដ៏ច្រើននេះ"[89]។ ម្យ៉ាងវិញទៀត មាត្រានេះចែងថា "លក្ខន្តិកៈនេះមិនបានបញ្ជាក់ (ឲ្យបានច្បាស់ ឬក៏ថ្លែងសំដៅទៅលើ) អំពីកត្តាអត្តនោម័តិ និងសត្យានុម័តិ (actus reus និង mens rea) នៃប្រភេទបទឧក្រិដ្ឋរួមគ្នានេះ"[90]។ លក្ខន្តិកៈនេះគ្រាន់តែផ្តល់ជា*មូលដ្ឋានមិនច្បាស់លាស់មួយ*[91] នៃការចូលរួមជារួមក្នុងឧក្រិដ្ឋកម្ម មួយដោយដឹងថាជាគោលបំណង/ការរៀបគម្រោងរួមដែលអង្គជំនុំជម្រះ[92] បានហៅថាជា "ទម្រង់នៃការទទួលខុសត្រូវរបស់ជនសមគំនិត"។ កត្តាជាក់លាក់ជាច្រើននៃភាពទទួលខុសត្រូវនេះក្នុងទម្រង់សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី I , ទម្រង់ទី II និងទម្រង់ទី III ទោះបីជាយ៉ាងណាក៏ដោយ មិនអាចកាត់ចេញពីលក្ខន្តិកៈបានឡើយ ប៉ុន្តែទំនងជាចេញមកពីច្បាប់ (យុត្តិសាស្ត្រ) ទំនៀមទម្លាប់។ យុត្តិសាស្ត្របន្ទាប់បានអនុវត្តតាមទស្សនៈនេះយ៉ាងច្បាស់លាស់ ឬក៏យ៉ាងហោចណាស់នៅក្នុងគោលគំនិតដែលថា ទស្សនៈនេះចាត់ទុកសហកម្មឧក្រិដ្ឋកម្មរួមជាទម្រង់នៃការប្រព្រឹត្តក្នុងគោលគំនិតនៃមាត្រា ៧(១)[93]។ សារណាបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអនុវត្តតាមទស្សនៈនេះ[94] និងបន្ថែមទៅលើទស្សនៈនេះនូវទឡ្ហីករណ៍គោលនយោបាយដោយផ្អែកលើគោលបំណង ពោលគឺថា គោលបំណងរបស់ច្បាប់ អ.វ.ត.ក ក្នុងការ

---

89

90

91

92

93

94

00238379

D99/3/27

កាត់ទោស "មេដឹកនាំជាន់ខ្ពស់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ" និង "ជនដែលទទួលខុសត្រូវខ្ពស់បំផុត" អាចសម្រេចទៅបាន ប្រសិនបើសហកម្មឧក្រិដ្ឋកម្មរួមត្រូវបានអនុវត្ត[95]។ ទស្សនៈនេះមានភាពចន្លោះប្រហោងដោយសារហេតុផលជាច្រើន។ ទីមួយ ទស្សនៈនេះមានកង្វះខាតនៃភាពខុសគ្នាចំពោះទម្រង់ទាំងបីរបស់សហកម្មឧក្រិដ្ឋកម្មរួម។ សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី I ស្រដៀងគ្នាទៅនឹងការប្រព្រឹត្តិរួមក្នុងគោលគំនិតបែបប្រពៃណី ដូច្នេះហើយអាចត្រូវបានគេចាត់ទុកថាជា "ការប្រព្រឹត្ត" ស្ថិតនៅក្នុងអត្ថន័យនៃមាត្រា ៧(១) នៃ លក្ខន្តិកៈតុលាការ ICTY[96] ដោយឡែកសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី III គ្រាន់តែតម្រូវឲ្យមានភាពទទួលខុសត្រូវរបស់ជនសមគំនិតប៉ុណ្ណោះ និងមិនបានបញ្ចូលនូវការ ប្រព្រឹត្តឡើយ។ ចំណែកសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី II វិញ វាពឹងទៅលើថាតើវាស្ថិតនៅក្នុងគោល គំនិតនៃសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី I ឬសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី III (ដូចឯកសារយោងមុន I.6)។ ទីពីរ សារណារបស់សហព្រះរាជអាជ្ញាមិនត្រឹមតែមិនបានយកចិត្តទុកដាក់អំពីភាពខុសគ្នាទាំងនេះនៅ ក្នុងកិច្ចពិភាក្សារបស់ខ្លួនអំពីច្បាប់ អ.វ.ត.ក[97] ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទុកភាពខុសគ្នារវាងសហកម្មឧក្រិដ្ឋកម្មរួម I និង សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី II ឲ្យនៅចំហ នៅពេលដែលខ្លួនស្នើឲ្យចោទប្រកាន់ ឌុច ជាសហចារីក្នុងសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី (I) ឬចោទប្រកាន់ពីបទឧក្រិដ្ឋដែលជាបច្ច័យដែលមានលក្ខណៈធម្មជាតិ និងអាចគិតទុកជាមុននៃសហកម្មឧក្រិដ្ឋកម្ម (សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី III)[98]។ ទីបី សារណានោះបញ្ចូលទឡ្ហីករណ៍គោលនយោបាយជាមួយនឹងការបកស្រាយត្រង់ៗនៃមាត្រា២៩នៃច្បាប់ អ.វ.ត.ក ដែលទំនងជាមើលរំលងថាទស្សនៈទីមួយមិនអាចមានលក្ខណៈល្អប្រសើរជាងទស្សនៈទីពីរ។ ចុងក្រោយ សហព្រះរាជអាជ្ញាមិនបានកត់សំគាល់ថាមានទម្រង់ផ្លាស់គ្នានៃការចោទប្រកាន់មេដឹកនាំជាន់ខ្ពស់ ឧទាហរណ៍ *ការប្រព្រឹត្តិឧក្រិដ្ឋកម្មដោយប្រយោលផ្អែកទៅលើទ្រឹស្តី នៃការត្រួតត្រាតាមវិធីនៃរចនាសម្ព័ន្ធចាត់តាំងតាមឋានានុក្រម*។ នៅពេលដែលវាមានលក្ខណៈលើសពីវិសាលភាពនៃសារណានេះក្នុងការធ្វើវិភាគបន្ថែមទៀតអំពីទ្រឹស្តីនេះ វាមានសារៈសំខាន់ដែលត្រូវធ្វើការកត់សំគាល់ថា នាពេលថ្មីៗនេះទ្រឹស្តីនេះត្រូវបានគេទទួលស្គាល់ និងត្រូវបានពន្យល់ដោយអង្គបុរេជំនុំជម្រះ I[99]

---

95

96

97

98

99

របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ហើយថាទ្រឹស្តីនេះក៏អាចត្រូវបានគេយកមកអនុវត្តនៅចំពោះមុខ អ.វ.ត.ក ផងដែរ ពីព្រោះវាអាចត្រូវបានគេចាត់ទុកថាជាទម្រង់នៃការប្រព្រឹត្ត ពោលគឺការប្រព្រឹត្ត តាមរយៈមនុស្សម្នាក់ទៀត (សូមអានឲ្យបានលំអិតមាត្រា ២៥ [៣] [ក] alt.3 នៃលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ)[100]។

## II. ៣. តើការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួមមាននៅក្រោមច្បាប់ (អន្តរជាតិ) ទំនៀមទម្លាប់នៅពេលវេលាសមស្របដែរឬទេ?

អង្គជំនុំជម្រះសាលាឧទ្ធរណ៍លើករណី Tadić ប្រកាន់ទស្សនថា "សញ្ញាណនៃការរៀបផែនការរួមជាទម្រង់នៃភាពទទួលខុសត្រូវរបស់ជនសមគំនិត គឺត្រូវបានចែងយ៉ាងច្បាស់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ"[101]។ សារណារបស់សហព្រះរាជអាជ្ញាយកតាមទស្សននេះ ប៉ុន្តែ ទាំងអង្គជំនុំជម្រះសាលាឧទ្ធរណ៍ និងសហព្រះរាជអាជ្ញាមិនបានពិចារណាឲ្យបានគ្រប់គ្រាន់ទៅលើភាពផ្សេងគ្នារវាងទម្រង់ខុសគ្នានៃសហកម្មឧក្រិដ្ឋកម្មរួមឡើយ។ លើសពីនេះទៀត ដំណោះស្រាយនៃករណី ថាឌិច ចំពោះច្បាប់យុត្តិសាស្ត្រសង្គ្រាមលោកលើកទីII យ៉ាងហោចណាស់មាន "តម្លៃដែលអនុវត្តពីមុនមកមិនច្បាស់"[102]។ ដូច្នេះ ប្រសិនបើគេពិនិត្យមើលច្បាប់យុត្តិសាស្ត្រដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍លើករណី ថាឌិច បានធ្វើការវិភាគនោះ គេប្រាកដជាធ្វើការសន្និដ្ឋានពីរយ៉ាង : នៅពេលដែលសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី I និងសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទីទម្រង់ទី II មានមូលដ្ឋានមួយនៅក្នុងច្បាប់ទំនៀមទម្លាប់ (ឧទាហរណ៍ ច្បាប់ យុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីII) នេះមិនមែនជាយុត្តិសាស្ត្រសម្រាប់សហកម្មឧក្រិដ្ឋរួមទម្រង់ទី III ឡើយ[103]។ តាមទស្សនវិស័យបែបតក្កនុលោមដ៏ម៉ត់ចត់មួយ ការវិភាគដែលវាមិនមែនជាយុត្តិសាស្ត្រសម្រាប់សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី III គឺមិនមានលក្ខណៈចាំបាច់ទេ ដោយសារតែសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី III មិនត្រូវបានគេដាក់បញ្ចូលដូចដែលបានបង្ហាញខាងលើ (II.២.) ដោយមាត្រា ២៩(១) នៃច្បាប់ អ.វ.ត.ក។ ទោះបីជា

100

101

102

103

00238381



យ៉ាងណាក៏ដោយ ដើម្បីភាពពេញលេញ ស្ថានភាពទំនៀមទម្លាប់របស់ច្បាប់នោះនឹងត្រូវបានគេធ្វើការវិភាគផងដែរដូចខាងក្រោម។

## II. ៣.១. **សហកម្មខុក្រិដ្ឋកម្មរួមទម្រង់ទី** I

កថាខណ្ឌចុងក្រោយរបស់មាត្រា ៦ នៃលក្ខន្តិកៈតុលាការយោធាអន្តរជាតិ ញូរ៉ឹមប៊ើក (ITM) និងកថាខណ្ឌចុងក្រោយរបស់មាត្រា ៥ នៃលក្ខន្តិកៈតុលាការក្រុងតូក្យូ បានបង្កើតនូវការទទួលខុសត្រូវដ៏ទូលំទូលាយមួយដោយផ្អែកទៅលើផែនការរួមដែលបានចែងថា "មេដឹកនាំ អ្នករៀបចំ អ្នកញុះញ៉ង់ និងជនសមគំនិតដែលបានចូលរួមក្នុងការបង្កើត ឬអនុវត្តផែនការរួម ឬការសម គំនិតប្រព្រឹត្តឧក្រិដ្ឋកម្មណាមួយក្នុងចំណោមឧក្រិដ្ឋកម្មដែលបានបញ្ជាក់ពីខាងលើ ត្រូវតែទទួល ខុសត្រូវចំពោះអំពើទាំងអស់ ដែលបានអនុវត្តដោយជនណាក៏ដោយនៅក្នុងការអនុវត្តផែកការ រួមនោះ"។ មាត្រា II (២) នៃច្បាប់ Control Council Law លេខ ១០ ចែងថា ជនម្នាក់ដែល "បានប្រព្រឹត្ត" ឧក្រិដ្ឋកម្មមួយ គឺនៅពេលដែលជននោះ "(ឃ) ត្រូវបានជាប់ទាក់ទងទៅនឹងផែនការ ឬសហកម្ម ដែលពាក់ព័ន្ធនឹងការប្រព្រឹត្ត ឬ (ង) ជាសមាជិកនៃអង្គការ ឬក្រុម ដែលជាប់ទាក់ទងទៅនឹងការប្រព្រឹត្តឧក្រិដ្ឋបែបនេះណាមួយ"។ នៅលើមូលដ្ឋាននេះ យុត្តាធិការរបស់តុលាការនូរ៉ាំប៊ើកបានចាត់ទុកថា**ទម្រង់ណាមួយនៃការចូលរួម** _ រាប់ចាប់ត្រឹមពីមានការ យល់ព្រម រហូតដល់ការចូលរួមអនុវត្តផ្ទាល់ _ គឺមានលក្ខណៈគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ នៅក្នុងការកាត់សេចក្ដីប្រកបដោយយុត្តិធម៌ លក្ខណៈវិនិច្ឆ័យទាំងនេះត្រូវបានគេយកមកអនុវត្តបែបនេះ ដែលចុងចោទមិនបានប្រព្រឹត្តឧក្រិដ្ឋកម្មដោយផ្ទាល់ត្រូវបានចាត់ទុកថាជាជនសមគំនិត ដោយសារតែ**ការជាប់ពាក់ព័ន្ធក្នុងការអនុវត្តន៍ ឬការិយាធិបតេយ្យជាក់លាក់នៅក្នុងឧក្រិដ្ឋកម្មនៃប្រព័ន្ធណាស៊ី** (Nazi)។ ជាលើកដំបូង ប្រភេទនៃការទទួលខុសត្រូវ ដែលផ្អែកទៅលើការអនុវត្តន៍តាមបែបចាត់តាំងជាក់លាក់នៅក្នុងឧបករណ៍ការិយាធិបតេយ្យត្រូវបានបង្កើតឡើង :

> "បទចោទ (...) គឺ មានការចូលរួមដោយដឹងជាមុននៅក្នុងប្រព័ន្ធដែលគ្រប់គ្រងដោយរដ្ឋាភិបាលទូទាំងប្រទេសនៃភាពឃោរឃៅ និងអយុត្តិធម៌ ដោយរំលោភទៅលើច្បាប់

> មនុស្សជាតិ និងសង្គ្រាម ដែលត្រូវបានប្រព្រឹត្តនៅក្នុងឈ្មោះនៃច្បាប់ដោយអាជ្ញាធរ របស់ក្រសួងយុត្តិធម៌ និងតាមរយៈលិខិតតុបករណ៍តុលាការ”[104]។

ស្រដៀងគ្នានេះដែរ នៅក្នុងករណីសហរដ្ឋអាមេរិក ទល់នឹង Pohl និងការទទួលខុសត្រូវក្នុងការចូលរួមដទៃទៀត ត្រូវបានផ្អែកទៅលើការបែងចែកការអនុវត្តភារកិច្ចខុសៗគ្នា ដែលបញ្ចូលគ្នា ទៅអាចសម្រួល ឬជំរុញឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្ម។ សមាជិក-SS ដែលត្រូវបានគេចោទ ប្រកាន់ “បានប្រតិបត្តិ និងរក្សាសហកម្មដ៏ធំសម្បើមដែលបណ្តាលឲ្យមានការបាត់បង់អាយុជីវិតរបស់ពលករទាសករពីទឹកដីដែលត្រូវបានគេកាន់កាប់ និងឈ្លើយសឹករាប់លាននាក់ដោយខុសច្បាប់”[105]។
ដោយសង្ខេប :

> “ប្រតិបត្តិការសាំញ៉ាំ និងល្អិតល្អន់ ដូចជាការនិរទេស និងការសម្លាប់បំផុតពូជជនជាតិជ្វីហ្វ និងការរឹបអូសយកទព្យសម្បត្តិរបស់ពួកគេ គឺជាភារកិច្ចដ៏ច្បាស់លាស់សម្រាប់ មនុស្សច្រើនជាងមួយនាក់ (...)។ ដូចដែលរំពឹងទុក អ្នកចូលរួមជាច្រើនក្នុងកម្មវិធីនោះ ទម្លាក់ការទទួលខុសត្រូវពីម្នាក់ទៅម្នាក់។ អ្នកបង្ករបង្កើតកម្មវិធីនិយាយថា “ពិតណាស់ ដែលខ្ញុំបានគិតអំពីកម្មវិធីនោះ ប៉ុន្តែខ្ញុំមិនបានអនុវត្តវាឡើយ”។ អ្នកបន្ទាប់ក្នុងជួរនោះ និយាយថា “ខ្ញុំបានដាក់ផែនការនោះចេញនៅលើក្រដាស ហើយបានតាក់តែងវិធីសាស្ត្រ ពិសេសសម្រាប់អនុវត្ត ប៉ុន្តែវាមិនមែនជាគម្រោងការណ៍របស់ខ្ញុំឡើយ ហើយខ្ញុំមិនបាន អនុវត្តផែនការនេះដាក់ស្តែងទេ”។ អ្នកទីបីក្នុងជួរនោះនិយាយថា “ពិតណាស់ដែលខ្ញុំ បានបាញ់សម្លាប់មនុស្ស ប៉ុន្តែខ្ញុំគ្រាន់តែអនុវត្តបទបញ្ជាពីថ្នាក់លើតែប៉ុណ្ណោះ”។ អ្នកបន្ទាប់ក្នុងជួរនិយាយថា “ពិតណាស់ដែលខ្ញុំបានទទួលនូវទ្រព្យសម្បត្តិដែលរឹបអូសបានពីកម្មវិធីនេះនិងបានធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិទាំងនោះ និងបានបោះចោល ទ្រព្យសម្បត្តិទាំងនោះ ប៉ុន្តែខ្ញុំមិនបានលួចទ្រព្យសម្បត្តិនោះនិងមិនបានសម្លាប់ម្ចាស់ទ្រព្យសម្បត្តិនោះឡើយ។ ខ្ញុំគ្រាន់តែអនុវត្តបទបញ្ជាពីថ្នាក់លើតែប៉ុណ្ណោះ”។ ដើម្បីបញ្ជាក់ពីភាពស្របនិយម យើងសូមធ្វើការសន្មតថា មនុស្សទាំងបួននាក់នោះត្រូវបានចោទប្រកាន់ពីបទប្លន់ធនាគារ។

---

104

105

00238383

D99/3/27

> អំពើរបស់នរណាម្នាក់ក្នុងចំណោមអ្នកទាំងបួននោះ នៅក្នុងវិសាលភាពនៃផែនការរួមក្លាយជាអំពើរបស់អ្នកដទៃទៀតទាំងអស់"[106]។

នៅក្នុងការកាត់ទោសដ៏ល្បីល្បាញមួយនៃអង្គភាពពិសេស (Einsatzgruppen) ដែលភារកិច្ចរបស់អង្គភាពទាំងនោះគឺដើម្បី "សំអាត" ទឹកដីដែលត្រូវបានគេកាន់កាប់នៅប៉ែកបូព៌ាពី "កត្តា" ដែលត្រូវបានចាត់ទុកថាមានលក្ខណៈអន់ថោកទាបបែបជាតិពន្ធុ និងពូជសាសន៍ ដោយពួកណាស៊ី Telford Taylor ដែលជាប្រធានក្រុមប្រឹក្សាព្រះរាជអាជ្ញាបានលើកទឡ្ហីករណ៍ថា "អ្នកទាំងឡាយណាដែលទទួលការយល់ព្រមក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ឬអ្នកទាំងឡាយណាដែលជាប់ទាក់ទងនឹងផែនការ ឬសហកម្មដែលពាក់ព័ន្ធនឹងការប្រព្រឹត្តិ (...) និងអ្នកទាំងឡាយណា ដែលជាសមាជិករបស់អង្គការ ឬក្រុមមួយដែលពាក់ព័ន្ធនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្ម" ត្រូវទទួលខុសត្រូវជា "អ្នកសមគំនិត"[107]។ អង្គហេតុដ៏សំខាន់គឺថាជនជាប់ចោទ "ជាសមាជិកនៃអង្គភាព Einsatz ដែលបេសកកម្មដាច់ខាតរបស់ពួកគេដែលសមាជិកទាំងអស់បានដឹងឮ គឺដើម្បីអនុវត្តកម្មវិធីប្រហារជីវិតទ្រង់ទ្រាយធំមួយ។ សមាជិកណាដែលបានជួយបង្ករឲ្យអង្គភាពនេះដំណើរការ ដោយដឹងនូវអ្វីដែលត្រូវគេរៀបចំ គឺមានទោសអំពីបទឧក្រិដ្ឋដែលបានប្រព្រឹត្តដោយអង្គភាពនោះ"[108]។

ការលើកទឡ្ហីករណ៍របស់តុលាការនូវាំប៊ើកស្ដីអំពីការសន្មតបដិការី គឺធ្វើឲ្យយើងនឹកឃើញដល់ទ្រឹស្ដីអង់គ្លេសអំពីការរៀបគម្រោងរួម[109] ដែលនៅក្នុងផែនការ និងសហកម្មរួមមួយអាចជាមូលដ្ឋាននៃការសន្មត។ ទ្រឹស្ដីគម្រោងការណ៍រួមត្រូវបានយកមកអនុវត្តនៅក្នុងការកាត់ទោសឧក្រិដ្ឋកម្មសង្គ្រាមនៅអង់គ្លេស ដូចដែលបានចងក្រងជាឯកសារដោយគណៈកម្មការឧក្រិដ្ឋកម្ម សង្គ្រាមអង្គការសហប្រជាជាតិ។ ជាវិធានទូទៅមួយនៅពេលដែលគេយល់ថាវាមានលក្ខណៈ គ្រប់គ្រាន់ដែលចុងចោទត្រូវបាន "ជាប់ទាក់ ទងទៅនឹងការប្រព្រឹត្ត" ឧក្រិដ្ឋកម្មនៅក្នុងករណី នៃអ្នកចូលរួមជាច្រើន នោះការសន្មតបដិការីនៃបុគ្គលមានការរួមចំណែកដល់បទល្មើស (ចំបង) ត្រូវបានផ្អែកទៅលើអ្នកចូលរួមដែលមានគោលបំណង ឬផែនការរួមដែលស្ថិតនៅក្នុងអត្ថន័យនៃទ្រឹស្ដីគម្រោងការណ៍រួម។ ការសន្មត

106

107

108

109

បដិការីក៏ត្រូវបានគេទទួលស្គាល់ផងដែរក្នុងករណីនៃការបែងចែកភារកិច្ចអនុវត្តរវាងជនសមគំនិង។ ករណីសំខាន់បំផុតចំពោះបញ្ហានេះ គឺករណី Almelo ដែលចៅក្រមតុលាការយោធា (Judge Advocate) បានលើកឡើងករណីថា វត្តមានរបស់ជនជាប់ចោទទាំងបួននាក់ក្នុងការសម្លាប់ឈ្លើយសឹកម្នាក់ (ដោយឡែក "នៅពេលទន្ទឹមគ្នានោះដែរបានចូលរួមក្នុងសហកម្មរួម") គឺមានលក្ខណៈគ្រប់គ្រាន់សម្រាប់អ្នកចូលរួមទាំងអស់នោះក្នុងការទទួលខុសត្រូវចំពោះការសម្លាប់ ដោយសារតែ "សកម្មភាពរបស់បុគ្គលម្នាក់ៗ" បានជួយដល់ "គោលបំណងរួមរបស់បុគ្គលទាំងអស់"[110]។ នៅក្នុងករណីដទៃទៀត ការទទួលខុសត្រូវក៏ផ្អែកផងដែរទៅលើអត្ថិភាពនៃគោលបំណង ឬផែនការរួម[111] ហើយលើសពីនេះទៀតផ្អែកទៅលើ "អ្វីដែលត្រូវបានជាប់ពាក់ព័ន្ធ" នៅក្នុងបទល្មើសព្រហ្មទណ្ឌនីមួយៗ[112]។ ដូច្នេះ សរុបមកវាអាចត្រូវបានគេធ្វើការសន្និដ្ឋានបានថា ការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី I ត្រូវបានទទួលស្គាល់រួចហើយដោយច្បាប់យុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី II ហើយដូច្នេះវាក៏បានកើតមានឡើងផងដែរនៅពេលដែលមានការប្រព្រឹត្តឧក្រិដ្ឋកម្មដែលមានក្នុងប្រទេសកម្ពុជា។

## II. ៣.២. សហកម្មឧក្រិដ្ឋកម្មទម្រង់ទី II

ចំពោះករណីជំរំប្រមូលផ្តុំ ដែលគ្របដណ្តប់ដោយសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី II ច្បាប់យុត្តិសាស្ត្រដែលពាក់ព័ន្ធក៏ត្រូវបានចងក្រងជាឯកសារផងដែរដោយគណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមអង្គការសហប្រជាជាតិ។ នៅក្នុងការជំនុំជម្រះក្តីលើករណីជំរំប្រមូលផ្តុំ Dachau[113] ជនជាប់ចោទទាំងអស់ត្រូវបានគេផ្តន្ទាទោសដោយផ្អែកលើមូលដ្ឋាននៃគោលគំនិតនៃ "ការប្រព្រឹត្តអនុលោមទៅនឹងគម្រោងការណ៍រួម"[114]។ យោងទៅលើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ប្រធានព្រះរាជអាជ្ញា "ការសួរសំណួរដែលត្រូវបានគេយកមកអនុវត្តគឺមិនមែន តើគាត់បានសម្លាប់ ឬបានវាយ ឬបានធ្វើទារុណកម្ម ឬបានបង្អត់បាយ ប៉ុន្តែសួរថា តាមការអនុវត្តរបស់គាត់ តើគាត់បានជួយជំរុញ

110

111

112

113

114

ឲ្យមានការអនុវត្តនូវគម្រោងការណ៍រួម និងបានចូលរួមនៅក្នុងនោះដែរឬទេ?[115]។ ការកាត់ទោសត្រូវតែបង្ហាញថា (១) នៅក្នុង Dachau មានប្រព័ន្ធមួយសម្រាប់ធ្វើបាបអ្នកទោស ឬការប្រព្រឹត្តិឧក្រិដ្ឋកម្មផ្សេងទៀត (២) ជនជាប់ចោទនីមួយៗបានដឹងអំពីប្រព័ន្ធនេះ និង (៣) បានជួយលើកទឹកចិត្តជួយជំរុញ ឬបានចូលរួមក្នុងការអនុវត្តប្រព័ន្ធនេះ[116]។ ប្រសិនបើជនជាប់ចោទម្នាក់គ្រាន់តែបានអនុវត្ត "សកម្មភាពអព្យាក្រឹត" នៅក្នុងប្រព័ន្ធនេះ ឧទាហរណ៍ បុគ្គលិក ផ្តល់សេវា ឬបុគ្គលិកពេទ្យ ការកាត់ទោសនោះត្រូវតែបង្ហាញថា ជននោះបានរំលោភទៅលើតួនាទីរបស់ខ្លួនក្នុងការធ្វើបាបអ្នកទោស[117]។ នៅក្នុងការជំនុំជម្រះក្តីលើករណី Belsen[118] ទាក់ទិនទៅនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងជំរំប្រមូលផ្តុំដ៏ល្បីល្បាញរបស់ Auschwitz និង Bergen-Belsen ចៅក្រមតុលាការយោធាក៏បានផ្អែកទៅលើគោលគំនិតនៃ "គម្រោងការណ៍ដែលបានធ្វើរួម" ឬ "ការព្រមព្រៀងរួម" ដើម្បីបង្កើតទឡ្ហីករណ៍របស់លោកចៅក្រមប្រឆាំងនឹងជនជាប់ចោទ :

> "ទឡ្ហីករណ៍សម្រាប់ការកាត់ទោសគឺថា ជនជាប់ចោទទាំងអស់ដែលបានបំរើការជា បុគ្គលិកនៅ Auschwitz បានដឹងថាប្រព័ន្ធមួយ និងដំណើរនៃការអនុវត្តមួយចូលជា ធរមាន ហើយថានៅក្នុងវិធីមួយ ឬវិធីផ្សេងទៀត*ក្នុងការជួយជ្រោមជ្រែងកិច្ចព្រមព្រៀងរួម* ក្នុងការរៀបចំជំរំនោះតាមបែបយង់ឃ្នង បុគ្គលទាំងអស់នោះបានចូលរួមក្នុងដំណើរការអនុវត្តន៍។ (...) ជនល្មើសជាក់ស្តែងកំពុងប្រព្រឹត្តដោយចេតនា ជាភាគីមួយក្នុងការជួយជ្រោមជ្រែងដល់ប្រព័ន្ធនេះ។ (...) ប្រសិនបើតុលាការជឿថា ពួកគេបានធ្វើបែបនោះមែន ដូច្នេះពួកគេម្នាក់ៗត្រូវតែទទួលខុសត្រូវចំពោះអ្វីដែលបាន កើតឡើង។ (...) នៅទូទាំងមន្ទីរឃុំឃាំងទាំងនោះ បុគ្គលិកទាំងអស់មានការយល់ដឹងយ៉ាងច្បាស់ថា អំពើឃោរឃៅការធ្វើបាប និងការប្រព្រឹត្តក្នុងទម្រង់នេះជាច្រើនទៀតនឹងមិនត្រូវបានគេដាក់ទណ្ឌកម្មទេ ប្រសិនបើពួកគេបានធ្វើឲ្យប៉ះពាល់ដល់ជនជាតិជ្វីហ្វ ហើយថា *មានគម្រោងការណ៍ដែលបានធ្វើរួមរបស់បុគ្គលិកក្នុងការប្រព្រឹត្តអំពើសាហាវទាំងនេះ*"[119]។

---

115

116

117

118

119

00238386

D99/3/27

នៅក្នុងករណីមណ្ឌលកុមារ Hadamar[120] និង Velpke[121] តុលាការត្រូវកាត់សេចក្តីទៅលើឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយជនជាប់ចោទជាជនស៊ីវិលក្នុងការអនុវត្តវិជ្ជាជីវៈរបស់ខ្លួន (ឧទាហរណ៍ជាគិលានុបដ្ឋាយិកា)។ មូលដ្ឋាននៃការសន្មតបដិការីអំពីអំពើរៀងៗខ្លួនរបស់ជន ជាប់ចោទ គឺហាក់បីដូចជាប្រព័ន្ធរួមនៃការធ្វើទុក្ខទោស និងការរំលោភបំពាន ដែលជនជាប់ចោទ បានចូលរួមដោយដឹងខ្លួនជាមុន។ ចំណែកឯករណី Hadamar ព្រះរាជអាជ្ញាបានលើកឡើងអំពី "រោងចក្រធ្វើឃាត" ដែល "អ្នកត្រូវមានមនុស្សជាច្រើនធ្វើកិច្ចការផ្សេងៗគ្នា (...) ហើយអ្នកមិន អាចបែងចែកភាពខុសគ្នារវាងជនដែលអាចបានទទួលគំនិតពីដំបូងអំពីការសម្លាប់មនុស្សទាំងនោះ និងជនដែលបានចូលរួមក្នុងការប្រព្រឹត្តបទល្មើសទាំងនោះឡើយ"[122]។ ជាលទ្ធផល "វាពិតណាស់ (...) ដែលជនណាក៏ដោយបានចូលរួមក្នុងបញ្ហានេះ មិនថាមានវិសាលភាពប៉ុនណានោះទេ គឺតាមបច្ចេកទេសត្រូវមានទោសពីបទចោទដែលគេចោទទៅលើជននោះ (...)។ ជនជាប់ចោទម្នាក់ៗ បានចូលរួមជាវិជ្ជមាន និងដោយចំហនៅក្នុង *បណ្តាញ* ដែលនាំឱ្យមានលទ្ធផលខុសច្បាប់បែបនេះ"[123]។

ជាចុងបញ្ចប់ "គោលបំណងរួម" ឬ "គម្រោងការណ៍រួម" ក៏ជាមូលដ្ឋានផងដែរនៃការ សន្មតក្នុងការកាត់ទោស Flossenburg[124] និង Mauthausen[125]។ យោងតាមការកាត់ទោស Mauthausen[126] គ្រាន់តែការងារនៅក្នុងជំរំប្រមូលផ្តុំ ឬក៏គ្រាន់តែមានវត្តមាននៅទីនោះ នាំឱ្យមានការសន្មតអំពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មសង្គ្រាម[127]។ ទោះបីជាយ៉ាងណាក៏ដោយ ការសន្មតនេះវាទៅឆ្ងាយពេកពីព្រោះវាបញ្ជាក់ពីភាពបញ្ច្រាសនៃការបង្ហាញភស្តុតាងចំពោះឧក្រិដ្ឋកម្មជាក់លាក់។ ពិតណាស់ជនជាប់ចោទដែលជាផ្នែកមួយនៃអង្គការរបស់ជំរំនោះ នឹងត្រូវតែបដិសេធនូវការសន្មតនោះ ដោយបង្ហាញថាគាត់មិនបានចូលរួមក្នុងឧក្រិដ្ឋកម្មជាក់លាក់នោះឡើយ[128]។

120
121
122
123
124
125
126
127
128

00238387

D99/3/27

ដោយយោងទៅតាមសេចក្តីអត្ថាធិប្បាយនៃគណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមអង្គការសហប្រជាជាតិ[129] ស្តីអំពីការកាត់ទោស Mauthausen មាន "អង្គហេតុ" ពីរ និង សេចក្តីសន្និដ្ឋានតាមអង្គច្បាប់មួយ។ ចំពោះអង្គហេតុពីរនោះ សេចក្តីអត្ថធិប្បាយនោះបាននិយាយថាការរៀបចំជំរំប្រមូលផ្តុំ Mauthausen បានបង្កើតឲ្យមាន "សហកម្មឧក្រិដ្ឋកម្មរួម" មួយ ហើយថា គ្រប់គ្នាដែលធ្វើការនៅក្នុងជំរំនោះ ឬក៏គ្រាន់តែមានវត្តមាននៅទីនោះ គឺដឹងអំពី "គម្រោងការណ៍រួម" និង លក្ខណៈឧក្រិដ្ឋនៃសហកម្ម។ តាមអង្គច្បាប់គេធ្វើការសន្និដ្ឋានថានរណាម្នាក់ដែលបានចូលរួមក្នុងសហកម្មឧក្រិដ្ឋ គឺមានទោសពីការរំលោភច្បាប់និងទំនៀមទម្លាប់នៃសង្គ្រាម។ សរុបមក ធាតុផ្សំរួមបីយ៉ាងក្នុងការបង្កើតឲ្យមានការទទួលខុសត្រូវមានចេញពីច្បាប់ យុត្តិសាស្ត្រដែលពាក់ព័ន្ធ :

- "មានប្រព័ន្ធជាធរមានដើម្បីប្រព្រឹត្តបទល្មើសជាក់លាក់"
- "ជនជាប់ចោទដឹងអំពីប្រព័ន្ធនោះ" និង
- "ជនជាប់ចោទបានចូលរួមប្រតិបត្តិប្រព័ន្ធនោះ"[130]។

## II. ៣.៣. សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី III

នៅពេលដែលការគិតពិចារណាដូចដែលបានរៀបរាប់ខាងលើបង្ហាញថា សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី I និងទម្រង់ទី II មានមូលដ្ឋានមួយនៅក្នុងច្បាប់យុត្តិសាស្ត្រក្រោយសង្គ្រាមលោក លើកទីII ក៏នេះមិនមែនជាករណីចំពោះសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទីIII ដែរ។ ច្បាប់យុត្តិសាស្ត្រ ដែលត្រូវបានគេយោងទៅលើដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍លើករណី ថាឌិច មានតែករណី Essen Lynching[131] តែប៉ុណ្ណោះដែលមានធាតុផ្សំនៃទ្រឹស្តី "គោលបំណងរួម" ឬ "គម្រោងរួម" តាមដែលការសម្លាប់នោះត្រូវបានគេសន្មតចំពោះជនជាប់ចោទទាំងអស់នៅលើមូលដ្ឋាននេះ (ផ្អែកលើអ្វីដែលត្រូវបានជាប់ពាក់ព័ន្ធរបស់ពួកគេនៅក្នុងការសម្លាប់ឈ្លើយសឹកជនជាតិអង់គ្លេសបីនាក់ដែលមិនត្រូវបានគេបង្ហាញអត្តសញ្ញាណ)។ ប៉ុន្តែ _ ក្នុងចំណោមករណីផ្សេងទៀតដោយសារតែចៅក្រមតុលាការយោធា (Judge Advocate) មិនបានធ្វើការសន្និដ្ឋាន _ វាមានលក្ខណៈមិនច្បាស់ ថាតើតុលាការបាន

129
130
131

00238388

D99/3/27

កាត់ទោសជនជាប់ចោទទាំងបីនាក់នោះដោយផ្អែកលើមូលដ្ឋាននៃគោលបំណងរួមស្តីអំពីការសម្លាប់របស់ជនជាប់ចោទ (ឧទាហរណ៍ អនុលោមតាមសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទីI) ឬក៏ _ ដូចដែលបានលើកឡើងដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍ លើករណី ថាឌិច[132] _ ផ្អែកលើមូលដ្ឋាននៃទ្រឹស្តីព្យាករដឹងជាមុន ឧទាហរណ៍ជនជាប់ចោទទាំងអស់អាចប្រមើលដឹងជាមុនថា (ដោយអត្តនោម័តិ ឬដោយសត្យានុម័តិ) អ្នកទោសនឹងត្រូវបានគេសម្លាប់។ នៅក្នុងលក្ខណៈស្រដៀងគ្នានេះដែរ ករណី Borkum Island[133] ដែលជាករណីមួយ ទៀតនៃការប្រើអំពើហិង្សារបស់ក្រុមមនុស្សបង្កើតជា _ ផ្អែកលើមូលដ្ឋាននៃករណីដែលបាន ធ្វើការចោទប្រកាន់ _ ភស្តុតាងនៃដំណោះស្រាយដល់សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទីI ជាជាង សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី III។ ការចោទប្រកាន់នេះបានពណ៌នាជនជាប់ចោទនៅក្នុងករណីនេះ ថាជា "ស្ពឺនៅក្នុងកង់នៃគម្រោងការណ៍រួម" កង់នីមួយៗចាំបាច់ចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្ម ("កង់នៃការធ្វើឃាតទាំងមូលមិនអាចវិលបានទេប្រសិនបើគ្មានស្ពឺទាំងអស់")។ ដូច្នេះគ្រប់គ្នាដែលត្រូវបានគេចោទប្រកាន់ ដែល "បានចូលរួមក្នុងផ្នែករៀងៗខ្លួននៅក្នុងការប្រើអំពើហិង្សារបស់ក្រុមមនុស្សដែលនាំឲ្យមានការសម្លាប់អ្នកបើកយន្តហោះជនជាតិអាមេរិកចំនួន ៧ នាក់ដោយខុស ច្បាប់" ត្រូវតែទទួលនូវការផ្តន្ទាទោសចំពោះឃាតកម្មនេះ[134]។ ដូច្នេះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ខ្លួនឯងទទួលស្គាល់ថាករណីនេះក៏អាចត្រូវបានគេចាត់ទុកជាករណីនៃសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទីI[135]។ ចុងក្រោយប៉ុន្តែមានសារៈសំខាន់ ការទទួលស្គាល់សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទីIII នៅក្នុងច្បាប់ទំនៀមទម្លាប់ក៏មិនអាចត្រូវបានគេកាត់ចេញពីច្បាប់យុត្តិសាស្ត្រប្រទេសអ៊ីតាលី ដែលត្រូវបានដកស្រង់ដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍[136]បានដែរ ដោយសារតែនៅក្នុងការជំនុំជម្រះក្តីនេះ _ ផ្ទុយទៅនឹងការជំនុំជម្រះក្តីនៅចំពោះមុខតុលាការយោធារបស់សហរដ្ឋអាមេរិក និងចក្រភពអង់គ្លេស _ មិនយកច្បាប់អន្តរជាតិមកអនុវត្ត ប៉ុន្តែយកតែច្បាប់ជាតិមកអនុវត្ត (មាត្រា ១១៦ [១] នៃក្រមព្រហ្មទណ្ឌប្រទេសអ៊ីតាលី[137])។ លើសពីនេះទៀត ច្បាប់យុត្តិសាស្ត្រ គឺ មានលក្ខណៈមិនដូចគ្នា

132
133
134
135
136
137

ដោយសារតែតុលាការកំពូលប្រទេសអ៊ីតាលី (Corte Suprema di Cassazione) បានអនុម័ត សេចក្តីសម្រេចពីរផ្សេងគ្នា[138]។

## II. ៤.តើការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួមមាននៅក្នុងច្បាប់ប្រទេសកម្ពុជានៅពេល សមស្របដែលពាក់ព័ន្ធនោះដែរឬទេ?

ច្បាប់ព្រហ្មទណ្ឌដែលមានជាធរមាននៅពេលវេលាដ៏សមស្រប គឺក្រមព្រហ្មទណ្ឌនៃប្រទេសកម្ពុជា ឆ្នាំ ១៩៥៦។ មិនទាន់មានការបកប្រែច្បាប់នេះជាភាសាអង់គ្លេស ឬជាភាសាបារាំងឲ្យបានពេញលេញនៅឡើយទេ ប៉ុន្តែមានការបកប្រែក្រៅផ្លូវការជាភាសាអង់គ្លេសសម្រាប់សារណានេះ។ ការបកប្រែនេះអាចផ្ទុយគ្នាទៅនឹងប្រភពពីរផ្សេងទៀតដែលអ្នកនិពន្ធមាន។

បើយោងទៅលើសេចក្តីអត្ថាធិប្បាយស្តីអំពី "ពង្រាងច្បាប់នៃក្រមព្រហ្មទណ្ឌថ្មី" ដែល សម្របសម្រួលដោយ Michel Bonnieu ច្បាប់របស់ប្រទេសកម្ពុជាចាស់បានបង្ហាញពីលក្ខណៈ ខុសគ្នារវាងចារីដែលមានគ្រោះថ្នាក់ និងចារីដែលមិនមានគ្រោះថ្នាក់ ("malfaiteur dangereux" និង "non dangereur") និងមាត្រា ៧៦ នៃក្រម ឆ្នាំ១៩២៩ និងក្រម ឆ្នាំ១៩៥៥ (១៩៥៦) បានឲ្យនិយមន័យពាក្យ "auteur" (ចារី) ថាជាអ្នកដែលប្រព្រឹត្តឧក្រិដ្ឋកម្ម ("infractions qu'ell commet …")[139]។ សហចារីកម្មត្រូវបានគេឲ្យនិយមន័យថាជា "ការប្រព្រឹត្តិរួម" (coaction) នៅក្នុងក្រម ឆ្នាំ១៩២៩ និងក្រមឆ្នាំ១៩៥៦ និងតម្រូវការសំខាន់បំផុតរបស់ពាក្យនេះ គឺការព្រមព្រៀងរួមរវាងសហចារី [140]។ ដូច្នេះតាមអត្ថន័យរបស់ពាក្យនេះ ការកំណត់នេះមិនបានព័ទ្ធវង់ អំពើនៅខាងក្រៅការព្រមព្រៀងឡើយ។ ទាំងនេះអាចត្រូវបានគេដាក់ទោសទណ្ឌត្រឹមតែជាការចូលដៃគ្នា[141]។ ជាក់ស្តែង យោងទៅលើការបកប្រែក្រៅផ្លូវការ មាត្រា ៨២ បង្ហាញពីភាពខុសគ្នា រវាងការចូលរួមដោយផ្ទាល់ និងដោយប្រយោល និងកំណត់ការចូលរួមដោយផ្ទាល់ថាជាសហចារីកម្ម និងកំណត់ការចូលរួមដោយប្រយោលថាជាការចូលដៃគ្នា។ យោងតាមមាត្រា ៨៧ ការជួយជំរុញ តម្រូវឲ្យមាន "ការជួយដោយ

138

139

140

141

មានការយល់ដឹងពេញលេញ"។ អ្នកដែលជួយជំរុញ អាចត្រូវបានគេគេចាត់ទុកថាជា សហចារី តែប៉ុណ្ណោះ "នៅពេលដែលជននោះដឹងអំពីបទល្មើសនោះ" ឧទាហរណ៍ នៅពេលដែលជននោះដឹង អំពីបទល្មើសនោះ។

សារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា យោងទៅលើមាត្រា ៨២ និង ១៤៥ នៃក្រម ឆ្នាំ១៩៥៦ ដែលបញ្ជាក់ថា មាត្រា ៨២ បង្ហាញពីលក្ខណៈខុសគ្នារវាង "ការប្រព្រឹត្តិរួម" និង "ការសមគំនិត"។ មាត្រា ១៤៥ ចែងអំពីនិយមន័យនៃពាក្យ "សហចារីកម្ម" ថាជា ចំនួនមនុស្ស ច្រើនដែល "ពិភាក្សា ឬពិគ្រោះ" ដោយមានទស្សនមួយក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម។ អ្នកជួយនិងជំរុញ ចាត់ទុកថាជាអ្នកសមគំនិត មិនមែនជាសហចារីទេ។ ក្រៅពីការយោងទៅលើមាត្រា ១៤៥ ដែលមិន ត្រូវបានបញ្ជាក់នៅក្នុងប្រភពដែលមានដទៃទៀតណាមួយនោះ សារណាបណ្តឹងឧទ្ធរណ៍បង្កើតជាថ្មី ទៀតដ៏ត្រឹមត្រូវនូវច្បាប់ដែលមានជាធរមាន នៅពេលដែលមានការប្រព្រឹត្តឧក្រិដ្ឋកម្ម។ ដោយច្បាប់ ព្រហ្មទណ្ឌបារាំងមានឥទ្ធិពលនៅក្នុងប្រទេសកម្ពុជា ដូច្នេះមិនមានការភ្ញាក់ផ្អើលទេដែលថា ក្រម ព្រហ្មទណ្ឌប្រទេសបារាំង (ក្រមព្រហ្មទណ្ឌប្រទេសបារាំង ឆ្នាំ១៨១០[142] មាត្រា ៥៩ មាត្រា ៦០) ដែលក្រមនោះមិនបានឲ្យនិយមន័យពីទម្រង់ខុសគ្នានៃការប្រព្រឹត្តឡើយ ដោយឡែកបង្ហាញពីភាពខុស គ្នារវាង"ចារី" និង "សហការី" (អ្នកជួយនិងជំរុញ អ្នកសមគំនិត) ហើយដូច្នេះ ក្រមនេះយ៉ាងហោច ណាស់បញ្ជាក់អំពីគំរូនៃការចូលរួមដែលក្រមនៃប្រទេសកម្ពុជាបានអនុវត្តតាម។

ដូច្នេះសរុបមក ចំពោះការទទួលស្គាល់អំពីការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួមនៅក្នុងច្បាប់ ប្រទេសកម្ពុជានៅពេលវេលាដ៏សមស្រប វាមានតែសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី I ប៉ុណ្ណោះបានកើត ឡើងយ៉ាងច្បាស់ ដោយឡែកសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី III ច្បាស់ណាស់ មិនត្រូវបានចែងក្នុង ក្រមឆ្នាំ១៩៥៦ ទេ។ ចំណែកសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី II អាស្រ័យថាតើគេបកស្រាយវាថាជា អនុប្រភេទនៃសហកម្មឧក្រិដ្ឋរួមទម្រង់ទី I ឬជាវិសាលភាព នៃការទទួលខុសត្រូវនៅក្នុងអត្ថន័យនៃ សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី III (សូមអានឯកសារយោងមុន I.៦ no.២)។

142

00238391

D99/3/27

**II. ៥. តើការទទួលខុសត្រូវដែលគេរកឃើញនោះ មានការដឹង និងព្យាករដឹងជាមុនគ្រប់គ្រាន់ដល់ចុងចោទនៅពេលវេលាសមស្របនោះដែរឬទេ?**

ដោយពិចារណាទៅលើគោលគំនិតខាងលើ ចម្លើយរបស់សំណួរចុងក្រោយនេះច្បាស់ ណាស់។ ទីមួយ មានតែសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី I និងទម្រង់ទី II ប៉ុណ្ណោះ មាននៅក្នុង ច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅពេលវេលាដ៏សមស្រប។ ដូច្នេះ បញ្ហាគឺដំបូងថាតើការទទួល ខុសត្រូវ ដែលបានផ្អែកទៅលើផែនការណ៍ គម្រោងការណ៍ ឬគោលបំណងរួម មានការដឹង និងប្រមើលដឹងជាមុនគ្រប់គ្រាន់ដល់ចុងចោទឬយ៉ាងណា។ អត្ថិភាពនៃការទទួលខុសត្រូវនេះ មិនត្រឹមតែស្ថិតនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិប៉ុណ្ណោះទេ ប៉ុន្តែក៏ _ ជា "ការប្រព្រឹត្តិរួម" _ ស្ថិតនៅក្នុងក្រមព្រហ្មទណ្ឌនៃប្រទេសកម្ពុជា បង្ហាញថាទម្រង់នៃការទទួលខុសត្រូវនេះបានដឹង និងបានព្យាករដឹងជាមុន។ ទីពីរ ចំពោះសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី II វាគ្រាន់តែកើតមានជាប្រភេទរងនៃសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី I នៅពេលវេលាសមស្រប ហើយគេអាចគ្រាន់តែចាត់ទុកថាជនជាប់ចោទបានដឹង និងបានព្យាករដឹងជាមុនគ្រប់គ្រាន់ប៉ុណ្ណោះ។